ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ







# កម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយ ២០០៩-២០១១



## ខេត្តព្រៃវែង

រៀបចំដោយ:
គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង
សហការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
និង មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី

មិថុនា ២០០៩

# មាតិកា


**អារម្ភកថា** ------------------------------------------------------------ iii

**ក្រុមការងារ**------------------------------------------------------------iv

**១. សេចក្តីផ្តើម**------------------------------------------------------------១

១.១-ប្រវត្តិគ្រោះទឹកជំនន់ ------------------------------------------------------------១

១.២ ការរៀបចំផែនការ និងសារៈសំខាន់ ------------------------------------------------------------៤

ក. ហេតុអ្វីបានជាត្រូវមានផែនការត្រៀមបង្ការគ្រោះទឹកជំនន់? ------------------------------------------------------------៤

ខ. តើផែនការត្រៀមបង្ការគ្រោះទឹកជំនន់អាចជួយយើងបានអ្វីខ្លះ? ------------------------------------------------------------៤

គ. អ្នកណាជាអ្នករៀបចំផែនការ? ------------------------------------------------------------៤

ឃ. តើផែនការនេះកើតឡើងយ៉ាងដូចម្តេច? ------------------------------------------------------------៥

ង. តើផែនការនេះសម្រាប់អ្នកណា? ------------------------------------------------------------៥

១.៣ ការកែសម្រួល និងការធ្វើបច្ចុប្បន្នភាព ------------------------------------------------------------៥

**២. ទិន្នន័យទូទៅរបស់ខេត្តព្រៃវែង**------------------------------------------------------------៦

២.១- ភូមិសាស្ត្រ និងទំហំផ្ទៃដី ------------------------------------------------------------៦

ក. ទីតាំងភូមិសាស្ត្រ ------------------------------------------------------------៦

ខ. ចំនួនស្រុក/ក្រុង ឃុំ/សង្កាត់ និង ភូមិ------------------------------------------------------------៦

គ. ផ្ទៃដីដី និងប្រភេទដី:------------------------------------------------------------៧

២.២ ទិន្នន័យប្រជាសាស្ត្រ------------------------------------------------------------៧

ក. ចំនួនប្រជាពលរដ្ឋ ------------------------------------------------------------៧

ខ. មុខរបរសំខាន់ៗរបស់ប្រជាជនផ្អែកតាមទិន្នន័យខែធ្នូ ឆ្នាំ២០០៧ ------------------------------------------------------------៩

គ. កម្រិតវប្បធម៌ ------------------------------------------------------------៩

ឃ. សេដ្ឋកិច្ច ------------------------------------------------------------ ១១

២.៣ ប្រវត្តិគ្រោះមហន្តរាយ ------------------------------------------------------------ ១៣

ក. ការវិភាគលើមុខសញ្ញាបង្កគ្រោះថ្នាក់ពីឆ្នាំ២០០០-២០០៨------------------------------------------------------------ ១៣

ខ. ការវិភាគភាពងាយរងគ្រោះ ------------------------------------------------------------ ១៤

គ. ផែនទីគ្រោះមហន្តរាយទឹកជំនន់ក្នុងឆ្នាំ២០០០របស់ខេត្តព្រៃវែង ------------------------------------------------------------ ១៥

២.៥ ធនធានសំខាន់ៗ ---------------------------------------------------------------------- ១៦
ក. សាលារៀន ----------------------------------------------------------------------- ១៦
ខ. មណ្ឌលសុខភាព និង មន្ទីរពេទ្យ--------------------------------------------------- ១៦
គ. ទីទួលសុវត្ថិភាព និង ទីតាំង ------------------------------------------------------ ១៦
ឃ. មធ្យោបាយដឹកជញ្ជូន--------------------------------------------------------------- ១៧
ង. ប្រព័ន្ធធារាសាស្ត្រ----------------------------------------------------------------- ១៨
ច. ប្រពន្ធ័ទំនាក់ទំនង ----------------------------------------------------------------១៩

**៣. ក្របខ័ណ្ឌការងារយោហ្គោសម្រាប់សកម្មភាព ឆ្នាំ២០០៥-២០១៥ និង ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ----------------------------------------------- ២១**
៣.១ ក្របខ័ណ្ឌការងារយោហ្គោសម្រាប់សកម្មភាពឆ្នាំ២០០៥-២០១៥---------------------------- ២១
៣.២ ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ---------- ២៣
៣.២.១ ក្របខណ្ឌ័ការងារនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ----------------------- ២៣
៣.២.២ តារាងសង្ខេបគម្រោងអាទិភាពកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ --------------------២៥

**៤. យន្តការស្ថាប័ន និង ការគ្រប់គ្រងគ្រោះមហន្តរាយ ---------------------------------------- ២៦**
៤.១ សមាសភាព ------------------------------------------------------------------ ២៦
៤.២ តួនាទី និង ការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ----------------- ២៦
៤.៣ រចនាសម្ព័ន្ធទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ------------------ ២៨
៤.៤ ក្រុមប្រតិបត្តិការ ----------------------------------------------------------------២៩

**៥. ផែនការសកម្មភាពរបស់មន្ទីរវិស័យសំខាន់ៗក្នុងខេត្តព្រៃវែង ទាក់ទិនវិធានការត្រៀមបង្ការ គ្រោះទឹកជំនន់សម្រាប់អនុវត្តរយៈពេល០៣ឆ្នាំៈ ពីឆ្នាំ២០០៩ ដល់ ឆ្នាំ២០១១ -------------------------------------- ៣៣**

**ឧបសម្ពន្ធ័**
១. ដីកាបង្កើត និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត
២. បញ្ជីឈ្មោះអង្គការជាតិ-អន្តរជាតិនានាក្នុងខេត្តព្រៃវែង
៣. ផែនទីខេត្ត

# អារម្ភកថា

ក្រោមការជួយគាំទ្របច្ចេកទេសពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី(ADPC) និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ(NCDM)ដោយមានការជួយឧបត្ថម្ភថវិកាពីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសប្រទេសអាឡឺម៉ង់ (GTZ)តាមរយៈលេខាធិការដ្ឋានគណៈកម្មាធិការទន្លេមេគង្គ(MRCs)ដោយមានការសម្របសម្រួលពីគណៈកម្មាធិការទន្លេមេគង្គជាតិកម្ពុជា (CNMC) ។ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង បានកែសម្រួល និងធ្វើបច្ចុប្បន្នភាពលើផែនការត្រៀមបង្ការគ្រោះទឹកជំនន់ថ្នាក់ខេត្តរបស់ខ្លួន ដែលបានរៀបចំឡើងតាំងពីឆ្នាំ២០០៧មកនោះ ឱ្យកាន់តែមានលក្ខណៈស៊ីជម្រៅ និងច្បាស់លាស់ថែមទៀត ពិសេសបានកែសម្រួលពីផែនការដែលមានលក្ខណៈរួមមកជាផែនការសកម្មភាពអាទិភាពតាមមន្ទីរវិស័យជុំវិញខេត្តវិញ សម្រាប់អនុវត្តបន្តរយៈពេលបីឆ្នាំ គឺចាប់ពីឆ្នាំ ២០០៩ ដល់ ឆ្នាំ ២០១១។

ផែនការនេះ ជាផែនការមេសម្រាប់អនុវត្តលើកម្មវិធីគ្រប់គ្រងគ្រោះទឹកជំនន់ថ្នាក់ខេត្ត ចែកចេញជាបីដំណាក់កាលសំខាន់ៗ (១).ដំណាក់កាលត្រៀមបង្ការមុនពេលទឹកជំនន់ (២).ដំណាក់កាលឆ្លើយតបក្នុងពេលទឹកជំនន់ និង (៣). ដំណាក់កាលស្តារនិងជួសជុលឡើងវិញក្រោយពេលទឹកជំនន់។ ការរៀបចំផែនការត្រៀមបង្ការគ្រោះទឹកជំនន់នេះ មានការចូលរួមយ៉ាងសកម្មពីថ្នាក់ដឹកនាំខេត្ត មន្ទីរវិស័យ និងអង្គភាពជុំវិញខេត្ត ដែលជាសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង និងមានការចូលរួមពីបណ្តាអង្គការជាតិ-អន្តរជាតិ ដែលបាននឹងកំពុងប្រតិបត្តិការការងារនៅក្នុងខេត្តព្រៃវែង ផងដែរ។

ផែនការត្រៀមបង្ការគ្រោះទឹកជំនន់នេះ ជាយុទ្ធសាស្រ្តមួយរបស់ខេត្ត សំដៅធានាដល់ការកាត់បន្ថយផលប៉ះពាល់ពីគ្រោះទឹកជំនន់មកលើវិស័យសេដ្ឋកិច្ច សុខមាលភាពរបស់ប្រជាពលរដ្ឋ-សត្វ ហេដ្ឋារចនាសម្ព័ន្ធជាតិ និងជនបទរបស់ខេត្តឱ្យមានប្រសិទ្ធភាពនិងទាន់ពេលវេលា ក៏ដូចជា ចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រនិងធ្វើឱ្យសម្រេចជោគជ័យនូវ **"យុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា"**។

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង សូមកោតសសើរដោយស្មោះ និង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្ម ក្នុងការរៀបចំកែសម្រួល និង ធ្វើបច្ចុប្បន្នភាពលើផែនការនេះឱ្យកើតចេញជារូបរាងឡើងកាន់តែមានលក្ខណៈពេលលេញ។ លើសពីនេះទៀត ក៏សូមថ្លែងអំណរគុណចំពោះ ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសប្រទេសអាឡឺម៉ង់ ដែលបានផ្តល់ថវិកាគាំទ្រដល់ការរៀបចំផែនការនេះតាំងពីជំហានទី១ ក៏ដូចជាការកែសម្រួលក្នុងជំហានទី២នេះ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ មន្ទីរវិស័យ-អង្គភាពជុំវិញខេត្ត ដែលជាសមាជិកគណៈ

កម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង ព្រមទាំងអង្គការជាតិ-អន្តរជាតិនានាក្នុងខេត្ត ដែលបានចូលរួមយ៉ាងសកម្មក្នុងដំណើរការរៀបចំផែនការនេះឡើង ។

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង មានជំនឿយ៉ាងមុតមាំថា នឹងអនុវត្តផែនការត្រៀមបង្ការគ្រោះទឹកជំនន់សម្រាប់រយៈពេលបីឆ្នាំ(២០០៩-២០១១)នេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ព្រៃវែង, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៩

**អភិបាលនៃគណៈអភិបាលខេត្ត**

**និងជា**

**ប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត**

**អ៊ុង-សាមី**

# ក្រុមការងារ

កម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយខេត្តព្រៃវែង ត្រូវបានកែសម្រួលនិងធ្វើបច្ចុប្បន្នភាព ដោយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ក្រោមកិច្ចគាំទ្របច្ចេកទេសពី គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) និង មជ្ឈមណ្ឌលត្រៀមបង្ការ គ្រោះមហន្តរាយអាស៊ី(ADPC) ដូចមានសមាសភាពខាងក្រោម៖

- **សមាសភាពក្រុមការងារ៖**

១ . លោក អ៊ុំ ប៊ុនឡេង — នាយខុទ្ទកាលយសាលាខេត្ត និង ជាលេខាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង

២. លោក សុទ្ធ គីមកុលមុនី — មន្ត្រីលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

៣. លោក ហ៊ុល ចំរើន — លេខាធិការរង នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង

៤. លោក អុល សែន — មន្ត្រីសម្របសម្រួលកម្មវិធី នៃមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី

- **ពិនិត្យតាមដាន និងផ្តល់បច្ចេកទេស៖**

១. ឯ.ឧ. ប៉ុន ណារិទ្ធិ — អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

២. ឯ.ឧ អ៊ុង សាមី — អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង

៣. លោក ជុំ វុទ្ធី — ប្រធានគម្រោងថ្នាក់ជាតិ នៃមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី

**ស្ថាប័នដែលបានចូលរួមចំណែក៖**

- មន្ទីរ និង អង្គភាព ដែលជាសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង
- តំណាងអង្គការជាតិ-អន្តរជាតិ ក្នុងខេត្តព្រៃវែង

# ផែនការត្រៀមបង្ការគ្រោះមហន្តរាយ
# ខេត្តព្រៃវែង

## ១. សេចក្តីផ្តើម

### ១.១. ប្រវត្តិគ្រោះទឹកជំនន់

ទន្លេមេគង្គ ជាអាយុជីវិតរបស់ប្រជាជនកម្ពុជា ។ ទន្លេមេគង្គ និង ដៃរបស់វា និង ទឹកភ្លៀងដ៏ច្រើនលើសលប់ ជាហេតុធ្វើឱ្យមានទឹកជំនន់ប្រចាំឆ្នាំ ប៉ះពាល់មកលើតំបន់ដែលមានផ្ទៃក្រលា ប្រហែល ១៧.១០០ គីឡូម៉ែត្រ ឬ ស្មើនឹង ២៥ ភាគរយនៃផ្ទៃដីទំនាបនៃអាងទន្លេមេគង្គ ។ ភ្លៀងធ្លាក់ខ្លាំង នៅរដូវវស្សា និង ការកាប់បំផ្លាញព្រៃឈើ បានធ្វើឱ្យមានទឹកជំនន់លឿន។ ជាញឹកញាប់លំហូរទឹកទន្លេមេគង្គមានភាពខ្ពស់ជាងច្រាំងទន្លេ ដោយសារតែមានភ្លៀងធ្លាក់ខ្លាំង មានទឹកហូរមកចាក់ក្នុងអាងទន្លេបានធ្វើឱ្យមានទឹកជំនន់នៅតាមបណ្តាខេត្តដែលមានទីតាំងនៅតាមតំបន់ទំនាប។ តំបន់ប្រឈមមុខនឹងគ្រោះទឹកជំនន់ នៅជុំវិញភ្នំពេញ និង តំបន់មួយភាគធំចុះទៅព្រំដែនប្រទេសវៀតណាម មានផ្ទៃដីប្រមាណ ៧.០០០ គីឡូម៉ែត្រក្រលា ។ ខេត្តដែលប្រឈមមុខនឹងគ្រោះទឹកជំនន់ទន្លេមេគង្គរួមមាន ខេត្តស្ទឹងត្រែង ក្រចេះ កំពង់ចាម កណ្តាល ព្រៃវែង និង ស្វាយរៀង ។

ទឹកជំនន់នៅឆ្នាំ ២០០០ ត្រូវបានគេរាយការណ៍ថា មានសភាពធ្ងន់ធ្ងរជាងគេ នៅក្នុងរយៈពេលជាង ៧០ ឆ្នាំ ។ របាយការណ៍ផ្លូវការនេះ រៀបចំដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០០ បានឱ្យដឹងថា មានមនុស្សស្លាប់ចំនួន ៣៤៧ នាក់ (ក្នុងនោះ ៨០ ភាគរយ ជាកុមារ ) ប្រជាជនចំនួន ៧៥០.៦១៨ គ្រួសារស្មើនឹងមនុស្សចំនួន ៣.៤៤៨.៦២៩ នាក់ នៅក្នុង ២១ ខេត្ត និងក្រុង បានទទួលរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយទឹកជំនន់ ក្នុងនោះប្រជាជនចំនួន ៨៥.០០០ គ្រួសារស្មើនឹង មនុស្សចំនួន ៣៨៧.០០០ នាក់ បានជម្លៀសទៅស្នាក់នៅបណ្តោះអាសន្ននៅលើទីទួលសុវត្ថិភាព ។ លើសពីនោះទៀត ផ្ទះចំនួន ៣១៧ ៩៧៥ ខ្នងទទួលរងការប៉ះពាល់ ក្នុងនោះ ៧.០៦៨ ខ្នងត្រូវខូចខាតទាំងស្រុង ។ ដំណាំកសិកម្ម និង ដំណាំផ្សេង ៗ ទៀតចំនួន ៦៨៨.០២១ ហិចតា ត្រូវទទួលរងការប៉ះពាល់ និង ខូចខាត។ ផ្អែកតាមរបាយការណ៍របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គណៈរដ្ឋមន្ត្រីបានប៉ាន់ស្មាន និង វាយតំលៃពីផលប៉ះពាល់ និង ការខូចខាតសរុបអស់ប្រហែល ១៥៧ លានដុល្លា អាមេរិក ។ នៅឆ្នាំ ២០០១ ផលប៉ះពាល់ដោយទឹកជំនន់នៅក្នុងប្រទេសកម្ពុជាត្រូវបានគេវាយតំលៃថាអស់ប្រហែល ៣៦ លានដុល្លាអាមេរិក និង ទឹកជំនន់ ឆ្នាំ ២០០២ មានប្រជាជនចំនួនប្រហែល ១លានកន្លះ និង ផ្ទៃដីកសិកម្មចំនួន ៦.០០០ហិចតា ត្រូវបានទទួលការប៉ះពាល់ ។

ស្ថិតិ និង ទិន្នន័យសង្ខេប ពីផលប៉ះពាល់ទឹកជំនន់ឆ្នាំ ២០០០ :

- ផ្ទះទទួលរងការប៉ះពាល់ចំនួន ៣១៧.៤០០ ខូចខាតចំនួន ៧.០០០ ខ្នង
- **ផ្នែកអប់រំ សិក្សាធិការ** : សាលារៀនទទួលការខូចខាតចំនួន ៩៨៨ ខ្នង

- **ផ្នែកសុខភាព** : មណ្ឌលសុខភាពខូចខាតចំនួន ១៣៨ ខ្នង
- **ផ្នែកកសិកម្ម** : - ស្រូវទទួលរងការខូចខាត ចំនួន ៣៧៤.០០០ ហិចតា
  - ដំណាំផ្សេង ៗទទួលរងការខូចខាតចំនួន ៤៧.០០០ ហិចតា
  - សត្វពាហនៈ ស្លាប់ចំនួន ៣.៩០០ ក្បាល
- **ផ្នែកហេដ្ឋារចនាសម្ព័ន្ធ** :
  - ផ្លូវជាតិ និង ផ្លូវខេត្តទទួលការខូចខាតប្រវែង ២.៦០០ គីឡូម៉ែត្រ
  - ផ្លូវរថភ្លើង ១១៥ គីឡូម៉ែត្រ
  - ស្ពាន ១១៥ កន្លែង
  - អណ្តូងទឹក និង លូទឹក ១១.៩០០
  - ប្រព័ន្ធធារាសាស្ត្រ ១១៣ ម៉ែត្រ

គេទទួលស្គាល់ថា នៅក្នុងអាងទន្លេមេគង្គ ទឹកជំនន់បានកើតឡើងផ្ទួន ៗ បានធ្វើឱ្យសំបូរត្រី និង ជីវៈចំរុះ នៅក្នុងតំបន់ អាចផ្តល់ទឹក ផ្លូវនាវាចរ និង ធ្វើឱ្យដីកសិកម្មមានជីជាតិ។ ទាក់ទងនឹងតំបន់ដីសើមនៅតាមទំនាប ជាប្រភពសំខាន់សម្រាប់ជីវភាពរស់នៅរបស់ប្រជាជនរាប់លាននាក់សម្រាប់ប្រកបរបចិញ្ចឹមជីវិតនៅតាមតំបន់ដីសើមនេះ។

ទន្ទឹមគ្នានេះ ទឹកជំនន់ទន្លេមេគង្គបានបង្កឱ្យមានការបាត់បង់អាយុជីវិត ទ្រព្យសម្បត្តិ និង រំខាតដល់សកម្មភាពអភិវឌ្ឍន៍សង្គម និង ការបង្កបង្កើតផលរបស់ប្រជាជននៅតាមតំបន់អាងទន្លេមេគង្គនេះផងដែរ។ ដូច្នេះ សកម្មភាព និង វិធានការកាត់បន្ថយផលប៉ះពាល់គ្រោះទឹកជំនន់គួរត្រូវបានរៀបចំធ្វើ ដូចជា ការអន្តរាគមន៍ជាក់ស្តែង ការរៀបចំគោលនយោបាយ និង ការរៀបចំផែនការ ដើម្បីទាញយកផលប្រយោជន៍ពីទឹកជំនន់ ដើម្បីធានាការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៅក្នុងប្រទេស ។ដូចគ្នានេះដែរ ដើម្បីកាត់បន្ថយផលប៉ះពាល់លើអាយុជីវិត និង ទ្រព្យសម្បត្តិរបស់ប្រជាជន។ សកម្មភាព និង វិធានការដែលបានធ្វើកន្លងមកទាក់ទងនឹងការងារគ្រប់គ្រងគ្រោះទឹកជំនន់ គឺផ្តោតសំខាន់តែលើការងារប្រតិបត្តិការជំនួយសង្គ្រោះបន្ទាន់ តែការងារត្រៀមបង្ការ និង កាត់បន្ថយគ្រោះទឹកជំនន់ ជាការងារចាំបាច់ត្រូវធ្វើ និង យកចិត្តទុកដាក់បំផុត ដូចពាក្យចាស់លោកថា " ការពារប្រសើរជាងព្យាបាល" ពេលពេលណាដែលទឹកជំនន់បាននាំមកនូវផលប្រយោជន៍ជូនប្រជាជន។ តាមបទពិសោធន៍ពីអតីតកាលបានបង្ហាញឱ្យយើងដឹងថា ការចូលរួមយ៉ាងសកម្មពីគ្រប់មជ្ឈដ្ឋានដែលពាក់ព័ន្ធ និង ការចូលរួមជាភាគទានជាធនធានដែលអាចមានដើម្បីធ្វើឱ្យការអនុវត្តន៍កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់នៅតាមមូលដ្ឋាន វាអាចជួយឱ្យប្រជាជនអាចដោះស្រាយបានយ៉ាងមានប្រសិទ្ធិភាព និង ទាន់ពេលវេលាទៅនឹងគ្រោះទឹកជំនន់តាមរយៈវិធានការណ៍នានា។

តាមរបាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តបានឱ្យដឹងថា តាមបណ្តាឆ្នាំខាងលើ ទឹកជំនន់ទន្លេមេគង្គ និង ទន្លេតូចបានបង្កការប៉ះពាល់ និង បង្កការខូចខាតលើអាយុជីវិតមនុស្ស សត្វ សេដ្ឋកិច្ចសង្គម ហេដ្ឋារចនាសម្ព័ន្ធជាច្រើន ដូចមាននៅក្នុងរបាយការណ៍សង្ខេបដូចខាងក្រោម :

- **ផលប៉ះពាល់ឆ្នាំ ២០០០ :**
  - មនុស្សស្លាប់ ៦៨ នាក់
  - ប្រជាជនរងការប៉ះពាល់ ១៧.២៨១ គ្រួសារ ( ៦០០.០០០ នាក់)
  - ចំនួនឃុំទទួលរងគ្រោះ ១០១ ឃុំ ។
  - ចំនួនផ្ទះប៉ះពាល់ ១២៣.២៨៩ ខ្នង
  - ផ្ទះខូចខាតទាំងស្រុងចំនួន ៦៩៥ ខ្នង ។
  - ច្រាំងទន្លេបាក់ ៨០០ ម៉ែត្រ
  - ស្ពាន និង លូការប៉ះពាល់ ១២១ កន្លែង
  - ផ្លូវជាតិ និង ផ្លូវលំប្រវែង ១៣៨.៩៩៦ ម៉ែត្រ
  - ប្រព័ន្ធធារាសាស្ត្រខូចខាត ១៣.០៦៩ ម៉ែត្រ
  - ដំណាំកសិកម្មប៉ះពាល់ ១០៤.១៧៨ ហត ។
- **ផលប៉ះពាល់ឆ្នាំ ២០០១**
  - មនុស្សស្លាប់ចំនួន ៣៥ នាក់
  - មនុស្សរបួស ០៩ នាក់
  - ប្រជាជនប៉ះពាល់ ១៥.០៦០ គ្រួសារ
  - ឃុំប៉ះពាល់ចំនួន ៩៥ ឃុំ
  - ផ្ទះប៉ះពាល់ ៧៦.៤៣៤ ខ្នង
  - ផ្ទះត្រូវបំផ្លាញ ៣២៣ ខ្នង
  - ផ្ទៃដីកសិកម្មប៉ះពាល់សរុបចំនួន ១០៤.១៧៨ ហ.ត
- **ផលប៉ះពាល់ឆ្នាំ ២០០២**
  - បានសម្លាប់ ១២ នាក់
  - ប្រជាជនរងគ្រោះ ៩.៤៩៧ គ្រួសារ ( ៣៦.៨០២ នាក់
  - ឃុំទទួលប៉ះពាល់ចំនួន ៩៣
  - ផ្ទះប៉ះពាល់ចំនួន ២.២៤៦ ខ្នង
  - ផ្ទះខូចខាតទាំងស្រុង ៤៥ ខ្នង
  - ច្រាំងទន្លេបាក់ប្រវែង ៧០ ម៉ែត្រ
  - ដំណាំកសិកម្មប៉ះពាល់ ១៥.៨២០ ហត
  - ដំណាំខូចខាតទាំងស្រុង ចំនួន ៨៧១ ហត

## ១.២ ការរៀបចំផែនការ និងសារៈសំខាន់

### ក. ហេតុអ្វីបានជាត្រូវមានផែនការត្រៀមបង្ការគ្រោះទឹកជំនន់?

ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ជាវិធានការ ឬ សកម្មភាព សម្រាប់អនុវត្តជាមុន ដើម្បីធ្វើឱ្យការឆ្លើយតប និង ស្តារឡើងវិញពីផលប៉ះពាល់ដោយគ្រោះទឹកជំនន់បានទាន់ពេលវេលា និង មានប្រសិទ្ធិភាព។ ផែនការត្រៀមបង្ការគ្រោះទឹក ជំនន់មានទិសដៅ និង តួនាទីសំខាន់ ៗ ២ ដូចខាងក្រោម :

- វាយតំលៃធនធាន និង សមត្ថភាពដែលមានស្រាប់នៅគ្រប់ថ្នាក់ រួមមាន ថ្នាក់ខេត្ត ស្រុក ឃុំនិង ភូមិ។
- រៀបចំនិតិវិធីប្រតិបត្តិការស្តង់ដារ សម្រាប់ការងារត្រៀមបង្ការ ប្រតិបត្តិការឆ្លើយតបសង្គ្រោះ និង ស្តារឡើងវិញ ទាំងនៅមុនពេល ក្នុងពេល និង ក្រោយពេលមានគ្រោះទឹកជំនន់ *ឧទាហរណ៍* ដូចជា ការផ្តល់ពតិមាន ជាមុនពីគ្រោះថ្នាក់ដែលអាចកើតឡើងឱ្យទាន់ពេលវេលា ការជម្លៀសប្រជាជន និងទ្រព្យសម្បត្តិជាមុន ពីកន្លែង គ្រោះថ្នាក់ រៀបចំជំរកបណ្តោះអាសន្ន ការស្តុកទុកជំនួយសង្គ្រោះ និង ការរៀបចំប្រព័ន្ធ ទំនាក់ទំនងសម្រាប់ ប្រើប្រាស់នៅក្នុងដំណាក់កាល មុនពេល ក្នុងពេល និង ក្រោយពេលនៅពេលមាន គ្រោះមហន្តរាយកើតឡើង ។

### ខ. តើផែនការត្រៀមបង្ការគ្រោះទឹកជំនន់អាចជួយយើងបានអ្វីខ្លះ?

ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ អាចជួយឱ្យមានការរៀបចំ និង កំនត់ធនធានសម្រាប់ប្រើប្រាស់ក្នុងការឆ្លើយតបនិងស្តារឡើងវិញបានទាន់ពេលវេលា និង មានប្រសិទ្ធិភាព និង អាចកាត់បន្ថយផលប៉ះពាល់គ្រោះទឹកជំនន់បានជាអតិប្បរា ។ ការរៀបចំផែនការបានល្អអាចជួយយើង នៅក្នុងការងារមួយចំនួនដូចខាងក្រោមៈ

- សហគមន៍ងាយរងគ្រោះអាចទទួលពតិមានបានទាន់ពេលវេលា និង ទៀតទាត់ ដូចជា ពតិមានព្យាករណ៍ និង ពតិមានប្រកាសភាពអាសន្នជាដើម ។
- អាចធ្វើឱ្យស្ថាប័ន និង អង្គការដែលធ្វើការងារឆ្លើយតប អាចផ្តល់បានទាន់ពេលវេលា និង មានប្រសិទ្ធិភាព ដូចជា ជំរកបណ្តោះអាសន្ន ការថែទាំសុខភាព ទឹកស្អាត និង ម្ហូបអាហារជូនជនរងគ្រោះ។
- អាចកាត់បន្ថយផលប៉ះពាល់លើជីវភាពរស់នៅរបស់ប្រជាជន។
- អាចស្តារឡើងវិញបានទាន់ពេលវេលា នូវផលប៉ះពាល់លើហេដ្ឋារចនាសម្ព័ន្ធ។
- ធ្វើឱ្យមានកិច្ចសហការបានល្អ និង មានប្រសិទ្ធិភាពក្នុងចំណោមអង្គការ និង ស្ថាប័នពាក់ព័ន្ធ ក្នុងការឆ្លើយតបទៅនឹងគ្រោះទឹកជំនន់។
- អាចធ្វើឱ្យសហគមន៍វិលប្រឡប់ទៅរកស្ថានភាពរស់នៅដូចដើមវិញបានយ៉ាងឆាប់រហ័ស ។

### គ. អ្នកណាជាអ្នករៀបចំផែនការ?

ផែនការនេះរៀបចំឡើង ដោយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និង មន្ទីរ-អង្គភាពជាសមាជិករបស់ខ្លួនជុំវិញខេត្ត ក្រោមការគាំទ្របច្ចេកទេសពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

**ឃ. តើផែនការនេះកើតឡើងយ៉ាងដូចម្តេច?**

ដោយមានការជួយគាំទ្របច្ចេកទេសពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC) និង គណៈកម្មាធិការ ជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត បានរៀបចំកែសម្រួល និងធ្វើបច្ចុប្បន្នភាពលើ ផែនការត្រៀមបង្ការគ្រោះទឹកជំនន់របស់ខ្លួនដែលបានកសាងឡើងតាំងពីឆ្នាំ២០០៧ ដោយដំណើរការតាមការ រៀបចំកិច្ចប្រជុំណែនាំពីបច្ចេកទេសរៀបចំដល់ប្រធាននិងបុគ្គលិកជំនាញមកពីតាមមន្ទីរអង្គភាពជុំវិញខេត្ត ក៏ដូចជាចុះផ្តល់ ការណែនាំបន្ថែមពីក្រុមការងារនៅតាមមន្ទីរអង្គភាពខាងលើ។ បន្ទាប់មកផែនការដែលបានព្រាងតាមមន្ទីរអង្គភាពទាំង អស់ត្រូវបានអនុម័ត និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការ តាមរយៈសិក្ខាសាលាអនុម័តនិងផ្សព្វផ្សាយមួយដែលបានរៀបចំឡើង នៅថ្នាក់ខេត្ត។

**ង. តើផែនការនេះសម្រាប់អ្នកណា?**

ឯកសារផែនការនេះ ក្រោយពីបានរៀបចំបានពេញលេញ និង ទទួលបានការយល់ព្រមឱ្យប្រើប្រាស់ពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តហើយ ឯកសារនេះនឹងធ្វើការបែងចែក និង ផ្សព្វផ្សាយទៅដល់មន្ទីរ-អង្គភាព ដែលជាសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ដើម្បីអនុវត្តទៅតាមតួនាទី និង ការទទួលខុសត្រូវរបស់ខ្លួន ដូចបានកំនត់នៅក្នុងផែនការ ដើម្បីធ្វើឱ្យសំរេចបានទៅតាមទិសដៅ និង លទ្ធផលដូចបានកំណត់នៅក្នុងវិធានការ និង សកម្មភាពនិមួយៗ ។ ឯកសារផែនការនេះ នឹងធ្វើការផ្សព្វផ្សាយផងដែរដល់រាជរដ្ឋាភិបាលជាតិ ជាពិសេស គណៈកម្មាធិការ ជាតិគ្រប់គ្រងគ្រោមហន្តរាយ ដើម្បីបញ្ចូលផែនការនេះទៅក្នុងផែនការឆ្នាំនៃកម្មវិធីអភិវឌ្ឍន៍ជាតិ ខេត្ត ស្រុក និង ឃុំ។ លើសពីនេះទៀត ឯកសារផែនការនេះនឹងធ្វើការផ្សព្វផ្សាយដល់បណ្តាអង្គការជាតិ-អន្តរជាតិពាក់ព័ន្ធ ទាំងនៅក្នុង និង ក្រៅ ខេត្ត ដើម្បីបានទទួលការចូលរួមគាំទ្រទាំងផ្នែកថវិកា និង បច្ចេកទេសសម្រាប់ធានាធ្វើឱ្យផែនការអាចសំរេចបានលទ្ធផលល្អ និង គោលដៅដូចមានចែងក្នុងផែនការនេះ ។

## ១.៣ ការកែសម្រួល និងការធ្វើបច្ចុប្បន្នភាព

ក. ស្ថាប័នអនុវត្តផែនការ: គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត

ខ. ផែនការសម្រាប់ឆ្នាំ : ២០០៩-២០១១

គ. ស្ថាប័នទទួលខុសត្រូវលើការកែសម្រួល និង ធ្វើបច្ចុប្បន្នភាពផែនការ: គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ក្រោមជំនួយបច្ចេកទេសពី គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និង

មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី

ឃ. កាលបរិច្ឆេទកែសម្រួលផែនការ: ខែធ្នូ ឆ្នាំ ២០១១

## ២. ទិន្នន័យទូទៅរបស់ខេត្តព្រៃវែង

### ២.១~ ភូមិសាស្ត្រ និងទំហំផ្ទៃដី

#### ក. ទីតាំងភូមិសាស្ត្រ

ខេត្តព្រៃវែងត្រូវបានបែងចែកជា ១២ស្រុក និងក្រុង ០១ មាន ១១៣ឃុំ និង ០៣ សង្កាត់ មានភូមិសរុប ១.១៣៧ ភូមិ ។ មានព្រំប្រទល់ ខាងជើងទល់នឹងខេត្ត កំពង់ចាម ខាងកើតទល់នឹងខេត្តស្វាយរៀង ខាងត្បូងទល់នឹងប្រទេសវៀតណាម ខាងលិចទល់នឹងខេត្តកណ្តាល ។

ខេត្តព្រៃវែងមានទំហំដី ៤៨៨.៣០០ ហិចតា ក្នុងនោះផ្ទៃដីកសិកម្ម ៣១០.០០០ហិកតា ផ្ទៃដីដាំដំណាំរួមផ្សំមានចំនួន ១២.០០០ហ.ត, ផ្ទៃដីលំនៅដ្ឋាន ៤៥.៥១៨ហត, ផ្ទៃដីព្រៃ ១៩.៤៦១ ហត , ផ្ទៃដីសាធារណៈ ១០១.៣២១ហ.ត ។

- **តំបន់វាលទំនាប:**
  ស្ថិតនៅខាងលិចទីរួមខេត្ត លាតសន្ធឹងតាមបណ្តោយតាមដងទន្លេមេគង្គ និង ទន្លេតូចពីជើងទៅត្បូង កាត់ស្រុកស៊ីធរកណ្តាល ស្រុកពារាំង ស្រុកកំពង់លាវ ស្រុកពាមរក៍ និង ស្រុកពាមជរ៍ ហើយគ្របដណ្តប់ជិតពាក់កណ្តាលផ្ទៃដីស្រុកព្រៃវែង ស្រុកបាភ្នំ ស្រុកព្រះស្តេច ស្រុកកំពង់ត្របែក និងមួយចំណែកតូចនៃស្រុកកញ្ជ្រៀច ។

  តំបន់វាលទំនាប ជាដីសណ្តរទន្លេមេគង្គ ដីមានជីជាតិល្អ អំណោយផលច្រើនដល់ប្រជាពលរដ្ឋក្នុងតំបន់នេះ ក្នុងការបង្កបង្កើនផលស្រូវដើមរដូវ ស្រូវប្រាំង ពិសេសទៅទៀត ដំណាំរួមផ្សំ និងការនេសាទ ។

- **តំបន់វាលរាប:**
  ស្ថិតនៅប៉ែកខាងកើតទីរួមខេត្តមានស្រុកកញ្ជ្រៀច ស្រុកកំចាយមារ និងស្រុកមេសាង គ្របដណ្តប់ជាងពាក់កណ្តាលស្រុកព្រៃវែង ស្រុកបាភ្នំ ស្រុកព្រះស្តេច និង ស្រុកកំពង់ត្របែក ។

  ជាតំបន់ដីរបាយខ្សាច់ល្បប់ចាស់ ជាដីខ្សោះជីជាតិ ភាគច្រើនជាដីស្រូវវស្សា ជួបប្រទះនឹងគ្រោះរាំងស្ងួតជារៀងរាល់ឆ្នាំ ខ្វះប្រភពទឹកស្រោចស្រព ទិន្នផលទាប ប្រជាជនរស់នៅតំបន់នេះមានជីវភាពខ្វះខាតខ្លាំង ។

#### ខ. ចំនួនស្រុក/ក្រុង ឃុំ/សង្កាត់ និង ភូមិ

| ល.រ | ឈ្មោះស្រុក និងក្រុង | ចំនួនឃុំ/សង្កាត់ | ចំនួនភូមិ |
|---|---|---|---|
| ១ | ក្រុង ព្រៃវែង | ៣ សង្កាត់ | ១៥ |
| ២ | ស្រុកបាភ្នំ | ៩ ឃុំ | ១០៨ |
| ៣ | ស្រុកកំចាយមា | ៨ - | ១២៩ |
| ៤ | ស្រុកកំពង់ត្របែក | ១៣ - | ១២២ |

| | | | |
|---|---|---|---|
| ៥ | ស្រុកកញ្ជ្រៀច | ៨ - | ៩៥ |
| ៦ | ស្រុកមេសាង | ៨ - | ១១៨ |
| ៧ | ស្រុកពាមជរ៍ | ១០ - | ៥០ |
| ៨ | ស្រុកពាមរក៍ | ៨ - | ៤០ |
| ៩ | ស្រុកពារាំង | ១១ - | ៨៤ |
| ១០ | ស្រុកព្រះស្ដេច | ១១ - | ១៤៥ |
| ១១ | ស្រុកព្រៃវែង | ១១ - | ១៣៨ |
| ១២ | ស្រុកកំពង់លាវ | ៥ - | ២៩ |
| ១៣ | ស្រុកស៊ីធរកណ្ដាល | ១១ - | ៦០ |
| **សរុប** | | **១១៦** | **១១៣៧** |

### គ. ផ្ទៃដីដី និងប្រភេទដីៈ

- ផ្ទៃដីសរុប ៤៨៨.៣០០ ហិកតា
- ផ្ទៃដីកសិកម្ម ៣១០.០០០ ហិកតា
- ផ្ទៃដីព្រៃ ១៩.៤៦១ ហិកតា
- ផ្ទៃដីលំនៅដ្ឋាន ៤៥.៥១៨ ហិកតា
- ផ្ទៃដីសាធារណៈ ១០១.៣២១ ហិកតា
- ផ្ទៃដីដំណាំរួមផ្សំ ១២.០០០ ហិកតា

*ប្រភព : របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ ២០០៤ និង ទិសដៅការងារឆ្នាំ ២០០៥ របស់សាលាខេត្តព្រៃវែង*

## ២.២ ទិន្នន័យប្រជាសាស្ត្រ

### ក. ចំនួនប្រជាពលរដ្ឋ

ប្រជាពលរដ្ឋក្នុងខេត្តមាន ២៣៣.៨៦១គ្រួសារ ដោយមានចំនួនមនុស្សសរុប ១.១១៧.៦១៥នាក់ ក្នុងនោះស្រ្តី ៥៨០.៨២៦ នាក់ ប្រុស ៥៣៦.៧៨៩នាក់។ បើប្រៀបធៀបនឹងឆ្នាំកន្លងមក គឺចំនួនគ្រួសារមានកំណើន ៣.៤៣២គ្រួសារ (កើន២%) ចំណែកចំនួន មនុស្សកើន ១៣.៩១២នាក់ស្មើនឹង១,២៦%(ឆ្នាំទៅកើន២៨.១៦០នាក់ ស្មើនឹង៣%)។ ចំនួនមនុស្សអាយុ១៨ឆ្នាំឡើងសរុបមាន៦៨០.៦៧៤នាក់ក្នុងនោះស្រី៣៦១.៤០៦នាក់ ។

| ចំនួនគ្រួសារនិងប្រជាជន | ឆ្នាំ ២០០៤ | ឆ្នាំ ២០០៥ | ឆ្នាំ ២០០៦ | ឆ្នាំ ២០០៦ |
|---|---|---|---|---|
| ចំនួនគ្រួសារសរុបក្នុងខេត្ត | 223,519 គ្រួសារ | 226,435 គ្រួសារ | 230,429 គ្រួសារ | 233,861 គ្រួសារ |
| កើន/ថយ | | 1% | 2% | 1% |
| ចំនួនប្រជាជនសរុប | 1,065,550 នាក់ | 1,075,543 នាក់ | 1,103,703 នាក់ | 1,117,615 នាក់ |
| កើន/ថយ | | 1% | 3% | 1% |
| ចំនួនគ្រួសារដែលស្ត្រីជាមេគ្រួសារ | 40,400 គ្រួសារ | 40,291 គ្រួសារ | 41,467 គ្រួសារ | 41,541 គ្រួសារ |

តាមលទ្ធផលជំរឿនប្រជារាស្ត្រនាខែមីនា ឆ្នាំ២០០៨ ប្រជាពលរដ្ឋក្នុងខេត្តមានវត្តមាននៅម៉ោងសូន្យយប់ថ្ងៃទី៣ ខែមីនា សរុប ៩៤៧.៣៥៧នាក់ គឺអវត្តមាន ដល់ទៅ១៧០.២៥៨នាក់ ( ស្មើនឹង១៥,២៣% ) ។

**ក្រាហ្វិក: ភាគរយស្ត្រីនិងបុរសធៀបនឹងចំនួនប្រជាជនសរុបក្នុងខេត្តព្រៃវែង(ខែធ្នូឆ្នាំ២០០៧)**




ភាគរយស្ត្រីនៅតែមានច្រើនជាងបុរស បើទោះបីជាអាត្រាកើតរបស់ទារកទាំង២ភេទក្នុងឆ្នាំ២០០៧ មានស្រីកើត តិចជាងបុរសក៏ដោយ( កើតសរុប៩.២៥៨នាក់ក្នុងនោះស្រីកើត៤.៤៣៧នាក់ ប្រុសកើត៤.៨២១នាក់) ។ ប៉ុន្តែអាត្រាស្លាប់ មាន បហាក់ប្រហែលគ្នា( ស្រីស្លាប់១.៣៧៦នាក់ ប្រុសស្លាប់១.៣៩៤នាក់) ។

បើពិនិត្យទៅលើ ស្ថានភាពផ្លាស់ប្តូរលំនៅដ្ឋាន យើងឃើញថាសមាជិកគ្រួសារជាស្ត្រីដែលបានផ្លាស់ចូលមានចំនួនច្រើន ជាងស្ត្រីផ្លាស់ចេញ ជាក់ស្តែងស្ត្រីផ្លាស់ចូលមាន ១៧.១១៥នាក់ ហើយផ្លាស់ចេញមានតែ១១.៥២២នាក់( លំអៀង ៥.៥៩៣នាក់) ។

**ក្រាហ្វិក: ដង់ស៊ីតេប្រជាជនតាមបណ្តាស្រុក ឆ្នាំ២០០៦_២០០៨**

ដង់ស៊ីតេប្រជាជនឆ្នាំ២០០៦-២០០៨




ដង់ស៊ីតេប្រជាជនមានកម្រិត ២២៨,៨នាក់ ក្នុង១គីឡូម៉ែត្រក្រឡា កើន២នាក់ បើប្រៀបធៀបទៅនឹង ឆ្នាំកន្លងទៅដែលមាន ២២៦,៦នាក់។ ស្រុកដែលមានដង់ស៊ីតេចាប់ពី ២០០នាក់ ឡើងទៅមាន ១០ស្រុក ហើយស្រុកដែលមានដង់ស៊ីតេ ក្រោម២០០នាក់ មាន ២ស្រុកគឺ កំចាយមារ និងពាមជរ។ ស្រុកទាំង២នេះមានផ្ទៃដីបង្កបង្កើនផលស្រូវ

ច្រើន និងជាស្រុកជាប់ ព្រំដែនប្រទេសវៀតណាម។ ស្រុកមេសាងមានដង់ស៊ីតេខ្ពស់ជាងគេ បន្ទាប់មកមានកំពង់ត្របែក និងបាភ្នំ (ចន្លោះពី២៥០ នាក់ ទៅ២៨០នាក់។

## ខ. មុខរបរសំខាន់ៗរបស់ប្រជាជនផ្អែកតាមទិន្នន័យខែធ្នូ ឆ្នាំ២០០៧

| ប្រភេទមុខរបរ | សរុបថ្នាក់ខេត្ត | %ថ្នាក់ខេត្ត | %ឆ្នាំមុន |
|---|---|---|---|
| **គ្រួសារមានមុខរបរធ្វើកសិកម្មជាចំបង** | **217,101 គ្រួសារ** | **92.83%** | **94.13%** |
| គ្រួសារមានមុខរបរធ្វើស្រែជាចំបង | 213,934 គ្រួសារ | 91.48% | 92.87% |
| គ្រួសារមានមុខរបរដាំដំណាំរយៈពេលវែងជាចំបង | 31 គ្រួសារ | 0.01% | 0.01% |
| គ្រួសារមានមុខរបរដាំដំណាំរយៈពេលខ្លីជាចំបង | 1,743 គ្រួសារ | 0.75% | 0.58% |
| គ្រួសារមានមុខរបរដាំបន្លែជាចំបង | 186 គ្រួសារ | 0.08% | 0.27% |
| គ្រួសារមានមុខរបរនេសាទជាចំបង | 1,100 គ្រួសារ | 0.47% | 0.34% |
| គ្រួសារមានមុខរបរចិញ្ចឹមសត្វជាចំបង | 107 គ្រួសារ | 0.05% | 0.06% |
| គ្រួសារមានមុខរបរពីអនុផលព្រៃឈើជាចំបង | 0 គ្រួសារ | 0.00% | 0.00% |
| **គ្រួសារមានមុខរបរធ្វើសិប្បកម្មជាចំបង** | **1,117 គ្រួសារ** | **0.48%** | **0.40%** |
| គ្រួសារមានមុខរបរសិប្បកម្មផលិតសង្ហារឹមពីឈើ ផ្តៅ ឫស្សី | 32 គ្រួសារ | 0.01% | 0.02% |
| គ្រួសារមានមុខរបរសិប្បកម្មផលិតពីដែក កញ្ចក់ អាលុយមីញ៉ូម | 19 គ្រួសារ | 0.01% | 0.01% |
| គ្រួសារមានមុខរបរសិប្បកម្មផលិតគ្រឿងបរិភោគ | 37 គ្រួសារ | 0.02% | 0.02% |
| គ្រួសារមានមុខរបរសិប្បកម្មផលិតពោះវៀនកង់ ម៉ូតូ | 1 គ្រួសារ | 0.00% | 0.00% |
| គ្រួសារមានមុខរបរសិប្បកម្មត្បាញរវៃ ក្រមា ហូល... | 826 គ្រួសារ | 0.35% | 0.35% |
| គ្រួសារមានមុខរបរសិប្បកម្មផ្សេងៗ | 202 គ្រួសារ | 0.09% | 0.01% |
| **គ្រួសារប្រកបមុខរបរសេវាកម្មជាចំបង** | **9,980 គ្រួសារ** | **4.27%** | **3.62%** |
| គ្រួសារប្រកបមុខរបរជំនួញ | 5,458 គ្រួសារ | 2.33% | 2.36% |
| គ្រួសារប្រកបមុខរបរជាង | 838 គ្រួសារ | 0.36% | 0.34% |
| គ្រួសារប្រកបមុខរបរដឹកជញ្ជូន | 725 គ្រួសារ | 0.31% | 0.30% |
| គ្រួសារប្រកបមុខរបរសេវាកម្មផ្សេងៗ | 2,959 គ្រួសារ | 1.27% | 0.62% |
| **គ្រួសារដែលប្រកបមុខរបរមិនច្បាស់លាស់(ចំរុះ)** | **5,663 គ្រួសារ** | **2.42%** | **1.85%** |

ខេត្តមានគ្រួសារដែលមានមុខរបរចំបងពឹងផ្អែកតែទៅលើការដាំដុះស្រូវចំនួន ២១៣.៩៣៤គ្រួសារស្មើនឹង ៩១,៤៨%នៃចំនួនគ្រួសារសរុប។ ក្រៅពីនោះមានមុខរបរចំបងដាំដំណាំដទៃទៀតក្រៅពីស្រូវ១.៩៦០គ្រួសារ (ស្មើ ០,៨៤%) នេសាទ ១.១០០គ្រួសារ (ស្មើ ០,៤៧%) ចិញ្ចឹមសត្វ ១០៧គ្រួសារ(ស្មើ០,០៥%) សិប្បកម្ម ១.១១៧គ្រួសារ (ស្មើ០,៤៨%) សេវាកម្ម ៩.៩៨០គ្រួសារ (ស្មើ៤,២៧%) និងគ្រួសារដែលមានមុខរបរ មិនច្បាស់លាស់ (មុខរបរចំរុះ) ចំនួន ៥.៦៦៣គ្រួសារ ស្មើនឹង ២,៤២%(ឆ្នាំទៅគ្រួសារ ប្រភេទនេះ មានតែ ៤.២៦៥គ្រួសារគឺស្មើ១,៨៥%)។

ពត៌មាននេះមានការខុសគ្នាពីមន្ទីរកសិកម្មខេត្តដែលចំនួនគ្រួសារជាកសិករមានចំនួន តែ៨៥%នៃចំនួនគ្រួសារសរុប ក្នុងនោះគ្រួសារជាកសិករដែលប្រកបរបរកសិកម្មជាប្រភពចំណូលសំខាន់មាន៨០,៥%នៃចំនួនគ្រួសារកសិករសរុប។

## គ. កម្រិតវប្បធម៌

**ចំនួនសិស្សសរុប**

| ប្រភេទសិស្ស | សរុប (នាក់) | ស្រី (នាក់) | ប្រុស (នាក់) |
|---|---|---|---|
| មត្តេយ្យ | ៤.៨៣១ | ២.៣៤៩ | ២.៤៨២ |
| បឋមសិក្សា | ១៧៩.៥១៣ | ៨៤.២០១ | ៩៥៣១២ |
| មធ្យមសិក្សាបឋមភូមិ | ២៨.០៤៤ | ១២.៥៧៦ | ១៥.៤៦៨ |
| មធ្យមសិក្សាទុតិយភូមិ | ៣៣២៦៤ | ១៣៤៥៧ | ១៩៨០៧ |
| **សរុប** | **២៤៥.៦៥២** | | **១៣៣.០៦៩** |

## ស្ថានភាពអក្ខរកម្មនិងកម្មវិធីអក្ខរកម្ម (សរុបស្ថិតិឃុំ)

| កម្មវិធីអក្ខរកម្ម(ស្ថិតិឃុំ) | ដោយមន្ទីរ | ដោយអង្គការ | ដោយកម្មវិធី | សរុបរួម |
|---|---|---|---|---|
| ថ្នាក់អក្ខរកម្មកំពុងដំណើរការ | 42 ថ្នាក់ | 26 ថ្នាក់ | 20 ថ្នាក់ | 88 ថ្នាក់ |
| ចំនួនសិស្សអក្ខរកម្មកំពុងរៀន | 946 នាក់ | 612 នាក់ | 391 នាក់ | 1,919 នាក់ |
| ថ្នាក់អក្ខរកម្មបានបញ្ចប់ | 28 ថ្នាក់ | 19 ថ្នាក់ | 16 ថ្នាក់ | 63 ថ្នាក់ |
| ចំនួនសិស្សអក្ខរកម្មបានបញ្ចប់ | 584 នាក់ | 403 នាក់ | 249 នាក់ | 1,236 នាក់ |
| ចំនួនសិស្សអក្ខរកម្មបានបញ្ចប់ដោយប្រឡងជាប់ | 472 នាក់ | 203 នាក់ | 219 នាក់ | 894 នាក់ |

**ក្រាហ្វិក: ចំនួនថ្នាក់អក្ខរកម្មកំពុងដំណើរការនិងបានបញ្ចប់តាមបណ្តាស្រុកខណ្ឌ** (យោងស្ថិតិឃុំ)




**ក្រាហ្វិក: ចំនួនសិស្សថ្នាក់អក្ខរកម្មកំពុងដំណើរការនិងបានបញ្ចប់តាមបណ្តាស្រុកខណ្ឌ** (យោងស្ថិតិឃុំ)



## ស្ថានភាពអ្នកមិនចេះអក្សរ

| ស្ថានភាពអនក្ខរជន(យោងស្ថិតិភូមិ) | ចំនួនទាំងខេត្ត | %ថ្នាក់ខេត្ត | %ឆ្នាំមុន |
|---|---|---|---|
| អ្នកមិនចេះអក្សរសរុបអាយុពី១៥-៦០ឆ្នាំ | 75,412 នាក់ | 10.98% | 10.82% |
| ស្ត្រីមិនចេះអក្សរអាយុពី១៥-៦០ឆ្នាំ | 42,996 នាក់ | 6.26% | 6.19% |
| អ្នកមិនចេះអក្សរសរុបអាយុពី១៥-១៧ឆ្នាំ | 3,909 នាក់ | 4.77% | 5.07% |
| ស្ត្រីមិនចេះអក្សរអាយុពី១៥-១៧ឆ្នាំ | 2,036 នាក់ | 2.49% | 2.55% |
| អ្នកមិនចេះអក្សរសរុបអាយុពី១៨-២៤ឆ្នាំ | 10,782 នាក់ | 6.64% | 6.57% |
| ស្ត្រីមិនចេះអក្សរអាយុពី១៨-២៤ឆ្នាំ | 6,013 នាក់ | 3.70% | 3.65% |
| អ្នកមិនចេះអក្សរសរុបអាយុពី២៥-៦០ឆ្នាំ | 60,721 នាក់ | 13.72% | 13.55% |
| ស្ត្រីមិនចេះអក្សរអាយុពី២៥-៦០ឆ្នាំ | 34,947 នាក់ | 7.90% | 7.86% |

***សំគាល់*** : ភាគរយធៀបជាមួយចំនួនមនុស្សតាមក្រុមអាយុនិមួយៗ (មិនមែនធៀបជាមួយប្រជាជនសរុបឡើយ) ។ ដោយឡែក ភាគរយស្ត្រីមិនចេះ អក្សរ គិតធៀបចំនួនបុរស-ស្ត្រី ក្នុងចន្លោះអាយុនោះ ដើម្បីដឹងថា ក្នុងចំនួនភាគរយសរុប មានស្ត្រីមិនចេះអក្សរប៉ុន្មានភាគរយ ។

**ក្រាហ្វិក: អ្នកមិនចេះអក្សរសរុបអាយុពី១៥-៦០ឆ្នាំនិងស្ត្រីមិនចេះអក្សរអាយុពី១៥-៦០ឆ្នាំតាមបណ្តាស្រុកខណ្ឌ**




***សំគាល់*** : ភាគរយអនក្ខរជនស្ត្រី ធៀបជាមួយចំនួនបុរស-ស្ត្រី ស្ថិតក្នុងចន្លោះអាយុ១៥-៦០ឆ្នាំ ដើម្បីដឹងថា ក្នុងភាគរយសរុបនោះមានស្ត្រីប៉ុន្មានភាគរយ ។

## ឃ. សេដ្ឋកិច្ច

### ❑ កម្រិតអត្រានៃភាពក្រីក្រ:

គំរោងអត្តសញ្ញាណកម្មគ្រួសារក្រីក្រដែលគាំទ្រដោយក្រសួងផែនការនិង GTZ បានអនុវត្តនៅស្រុកចំនួន៤ ឃុំ ៣០ និងភូមិ ចំនួន២៥១ ដោយកំណត់តំបន់គោលដៅទៅតាមអាត្រាគ្របដណ្តប់របស់ស្រុកប្រតិបត្តិពារាំងនិងព្រះ ស្តេច ក្នុងនោះ (១) ស្រុកពារាំង គ្រប់ឃុំទាំង១១និងភូមិ៨៤ (២) ស្រុកស៊ីធរកណ្តាល១០ឃុំ ភូមិ៥៥ (៣) ស្រុក ព្រះស្តេច ៧ឃុំ ភូមិ៩៦ (៤) ស្រុកពាមជរ២ឃុំ ភូមិ១៦។ ក្រោយពីការចុះផ្សព្វផ្សាយពីនីតិវិធី និងដំណើរការរបស់គំរោង មន្ត្រីសម្របសម្រួល ខេត្តស្រុក បានដឹកនាំការងាររៀបចំបញ្ជីគ្រួសារក្រីក្រនៅតាមភូមិ ដោយតំណាងតាមភូមិនីមួយៗ

ចុះសម្ភាសន៍ផ្ទាល់ ទៅតាមលក្ខខណ្ឌនៃការកំណត់ពិន្ទុរបស់ក្រសួងផែនការ។ បញ្ជីគ្រួសារក្រីក្រត្រូវបានអនុម័តដោយក្រុមប្រឹក្សាឃុំ ដូចក្នុង តារាងខាងក្រោម ៖

| ល.រ | ឈ្មោះស្រុក | គ្រួសារសរុប | ក្រប្រភេទ១ | ភាគរយ | ក្រប្រភេទ២ | ភាគរយ | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|---|
| 1 | ពារាំង | 26819 | 2311 | 8.62% | 3874 | 14.44% | 6185 | 23.06% |
| 2 | ស៊ីធរកណ្ដាល | 13878 | 1672 | 12.05% | 2104 | 15.16% | 3776 | 27.21% |
| 3 | ព្រះស្ដេច | 16447 | 3234 | 19.66% | 3324 | 20.21% | 6558 | 39.87% |
| 4 | ពាមជរ | 2918 | 477 | 16.35% | 721 | 24.71% | 1198 | 41.06% |
| | **សរុប** | **60062** | **7694** | **12.81%** | **10023** | **16.69%** | **17717** | **29.50%** |

❑ **ស្ថានភាពស្ត្រីជាមេគ្រួសារ** ៖ (យោងស្ថិតិភូមិ)

| **ប្រភេទគ្រួសារដែលមាន ៖** | **សរុបថ្នាក់ខេត្ត** | **%ថ្នាក់ខេត្ត** | **%ឆ្នាំមុន** |
|---|---|---|---|
| ស្ត្រីជាមេគ្រួសារ | **41,541** គ្រួសារ | **17.76%** | **18.00%** |
| ស្ត្រីជាមេគ្រួសារមានកូនតូចអាយុតិចជាង៥ឆ្នាំ | **7,602** គ្រួសារ | **3.25%** | **3.36%** |

**ក្រាហ្វិក៖ <u>គ្រួសារដែលស្ត្រីជាមេគ្រួសារនិងមានកូនតូចអាយុតិចជាង៥ឆ្នាំ តាមបណ្ដាស្រុក</u>**




**ចំណាកស្រុក និង ស្វែងរកការងារធ្វើ** (យោងស្ថិតិភូមិ) ៖

| **បរិយាយ** | **សរុប** | **ស្រី** | **%សរុប** | **%ស្រី** |
|---|---|---|---|---|
| ចំនួនមនុស្សទៅរកស៊ីឬបម្រើការងារក្នុងក្រុមហ៊ុនរោងចក្រ (មុខរបរច្បាស់លាស់) | **65,903**នាក់ | **49,805**នាក់ | **5.90**% | **4.46**% |
| ចំនួនមនុស្សទៅរកស៊ីមិនដឹងពីមុខរបរច្បាស់លាស់ | **21,487**នាក់ | **6,775**នាក់ | **1.92**% | **0.61**% |
| សរុបចំនួនមនុស្សធ្វើចំណាកស្រុក | **87,390**នាក់ | **56,580**នាក់ | **7.82**% | **5.06**% |

**ក្រាហ្វិក៖ <u>មនុស្សទៅរកស៊ីក្រៅស្រុក តាមបណ្ដាស្រុក</u>** (យោងស្ថិតិភូមិ)




ដោយគ្រោះធម្មជាតិរាំងស្ងួត និងទឹកជំនន់ជួន១ជាប់គ្នា ៣ ឆ្នាំ ការប្រមូលផលបានតិចតួច ហើយខ្វះទុនសម្រាប់ ចំណាយក្នុងការដាំដុះ និង ខ្វះស្បៀងផងនោះ ប្រជាជនមួយចំនួនធំ ជាពិសេសមនុស្សពេញវ័យ បានចាកចេញពីលំនៅដ្ឋាន របស់ខ្លួនដើម្បីស្វែងរកការងារធ្វើតាមទីក្រុងធំ ៗ ដូចជា ទីក្រុងភ្នំពេញ កំពង់សោម សៀមរាប កោះកុង ប៉ោយប៉ែត និងខ្លះបានចូលទៅប្រទេសថៃ ។

## ២.៣ ប្រវត្តិគ្រោះមហន្តរាយ

### ក. ការវិភាគលើមុខសញ្ញាបង្កគ្រោះថ្នាក់ពីឆ្នាំ២០០០-២០០៨

| មុខសញ្ញាបង្កគ្រោះថ្នាក់ | ឥទ្ធិពល និង ភាពធ្ងន់ធ្ងរ | | | | | | | | | | ពេលវេលា | រយៈពេល | ល្បឿន | គ្រោះថ្នាក់ដែលអាចកើតឡើង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១៩៩៩ | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | | | | |
| ទឹកជំនន់ | x | xxx | xx | x x | x | x | x | x | x | x | មិថុនា-តុលា | ៣ ខែ | យឺត១ | - មនុស្ស<br>- ដំណាំកសិកម្មនិងឧស្សាហកម្ម<br>- សត្វ<br>- ហេដ្ឋារចនាសម្ព័ន្ធ និង អាគារ |
| រាំងស្ងួត | x | x | x | x | xxx | xxx | xx | x | x | x | កក្កដា-កញ្ញា | ៣ ខែ | យឺត១ | - មនុស្ស និង សត្វ (មានជំងឺ រាតត្បាត)<br>- ដំណាំកសិកម្មនិងឧស្សាហកម្ម |
| ខ្យល់ព្យុះ | x | x | x | x | x | x | x | x | x | x | កក្កដា-តុលា | | លឿន | - មនុស្ស និង សត្វ<br>- អាគារ ផ្ទះ និង ហេដ្ឋារចនាសម្ព័ន្ធ |
| គ្រុនផ្តាសាយបក្សី | | | | | | | x | x | | | | | យឺត ១ | - មនុស្ស<br>- សត្វ(មាន់ ទារ.........) |

*( ប្រភព : គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង )*

***កំណត់សំគាល់ :***

- xxx ទឹកជំនន់ធំ   xx ទឹកជំនន់មធ្យម   x ទឹកជំនន់តូច
- តំបន់ដែលរងគ្រោះដោយទឹកជំនន់មានស្រុក ស៊ីធរកណ្តាល ពារាំង កំពង់លាវ ពាមរក៏ និង ស្រុកពាមជរ៍ និង តំបន់មួយចំនួនទៀត ដូចជានៅក្នុងស្រុកកញ្ច្រៀច, ព្រៃវែង, បាភ្នំ, ព្រះស្តេច និងស្រុកកំពង់ត្របែក ហើយតំបន់

ទាំងនេះច្រើនមានគ្រោះថ្នាក់ច្រើនជាងគេគឺ ផ្ទះទាបៗ ឬ តៀមជាប់នឹងដី គ្មានទូក ការណួត និងលក្ខណៈត្រៀមបំរុង ដូចបណ្ដាស្រុកខាងលើ ។

- ទឹកលិចហើយស្រកមុនគេមានស្រុកស៊ីធរកណ្ដាល, ពារាំង, កញ្ជ្រៀច និងស្រុកព្រៃវែង ។
- ទឹកលិចក្រោយហើយស្រកក្រោយមានស្រុក កំពង់លាវ, ពាមរក៏, បាភ្នំ និងស្រុកពាមជរ៍ ហើយ ស្រុកព្រះស្ដេច និង ស្រុកកំពង់ត្របែក ស្រកក្រោយគេបង្អស់ ។

## ខ. ការវិភាគភាពងាយរងគ្រោះ

**ក្រុមជនងាយរងគ្រោះដែលត្រូវទទួលកិច្ចការពារពិសេស** (យោងស្ថិតិភូមិ)

| ប្រភេទជនងាយរងគ្រោះ | សរុបថ្នាក់ខេត្ត | សរុបឆ្នាំមុន |
|---|---|---|
| ចំនួនជនរងគ្រោះដោយសារការរំលោភផ្លូវភេទ | 30 នាក់ | 48 នាក់ |
| ចំនួនជនរងគ្រោះដោយសារជួញដូរមនុស្ស | 2 នាក់ | 36 នាក់ |
| ចំនួនគ្រួសារដែលមានសមាជិកប្រើប្រាស់គ្រឿងញៀន | 17 គ្រួសារ | 39 គ្រួសារ |
| ចំនួនគ្រួសារដែលមានសមាជិកកើតជំងឺអេដស៍ | 1,250 គ្រួសារ | 1,119 គ្រួសារ |
| ចំនួនកុមារកំព្រាអាយុក្រោម១៨ឆ្នាំដោយសារអេដស៍ | 2,234 នាក់ | 2,179 នាក់ |
| ចំនួនកុមារកំព្រាអាយុក្រោម១៨ឆ្នាំ (ទូទៅគ្រប់ករណី) | 4,368 នាក់ | 4,389 នាក់ |
| ចំនួនមនុស្សចាស់ជរាគ្មានទីពឹង | 1,539 នាក់ | 1,655 នាក់ |
| ចំនួនជនពិការអាចរកចំណូលបាន | 559 នាក់ | 574 នាក់ |
| ចំនួនជនពិការមិនអាចរកចំណូលបាន | 1,396 នាក់ | 1,231 នាក់ |
| ចំនួនជនពិការអាយុក្រោម១៨ឆ្នាំ | 652 នាក់ | 625 នាក់ |
| ចំនួនគ្រួសារដែលរងគ្រោះដោយគ្រោះធម្មជាតិ | 3,597 គ្រួសារ | 15,515 គ្រួសារ |
| ចំនួនជនរងគ្រោះដោយសារគ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ | 22 នាក់ | 70 នាក់ |

**ក្រាហ្វិក: <u>ចំនួនគ្រួសារដែលរងគ្រោះដោយគ្រោះធម្មជាតិតាមបណ្ដាស្រុក</u>**



## គ. ផែនទីគ្រោះមហន្តរាយទឹកជំនន់ក្នុងឆ្នាំ២០០០របស់ខេត្តព្រៃវែង



## ២.៥ ធនធានសំខាន់ៗ

### ក. សាលារៀន

- សាលាមត្តេយ្យរដ្ឋ មាន ១០៦ កន្លែង និងមត្តេយ្យសហគមន៍ ១៦១ ភូមិ
- បឋមសិក្សាមាន ៥២១ សាលា
- អនុវិទ្យាល័យ ៩៣ សាលា
- វិទ្យាល័យ ២៤ សាលា
- សាលាភាសា និងកុំព្យូទ័រឯកជន ២៨ កន្លែង
- មជ្ឈមណ្ឌលគរុកោសល្យ ០២ សាលា

### ខ. មណ្ឌលសុខភាព និង មន្ទីរពេទ្យ

| ស្រុកប្រតិបត្តិ | ចំនួន HCs | មណ្ឌលសុខភាព MPA | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ២០០៥ | ២០០៦ | ២០០៨. | ការគ្របដណ្តប់ (%) | គោលដៅចំណុច២០០៨ | |
| កំចាយមារ | 11 | 10 | 10 | 10 | 90.90 | 100% | មិនទាន់មានអគារ ១ |
| កំពង់ត្របែក | 11 | 7 | 7 | 7 | 63.63 | 100% | មិនទាន់មានអគារ ២ |
| មេសាង | 10 | 10 | 10 | 10 | 100 | | |
| អ្នកលឿង | 17 | 11 | 11 | 11 | 64.70 | 100% | មិនទាន់មានអគារ ៦ |
| ពារាំង | 15 | 15 | 15 | 15 | 100 | | |
| ព្រះស្តេច | 9 | 9 | 9 | 9 | 100 | | |
| ព្រៃវែង | 17 | 9 | 9 | 10 | 58.82 | 100% | មិនទាន់មានអគារ ៨ |
| សរុប | 90 | 71 | 71 | 72 | 80% | 100% | មិនទាន់មានអគារ ១៧ |

### គ. ទីទួលសុវត្ថិភាព និង ទីតាំង

| ឈ្មោះស្រុក | ចំនួនសរុប | ទីទួលដែលមានអណ្តូងទឹកស្អាត និង បង្គន់អនាម័យ |
|---|---|---|
| បាភ្នំ | ៣៤ | ១០ |
| កំពង់ត្របែក | ២៦ | ០១ |
| ពាមជរ៍ | ៤៧ | ០២ |
| ពាមរក៍( អ្នកលឿ) | ៥០ | ០៦ |
| ពារាំង | ៤៧ | ០ |

| | | |
|---|---|---|
| ព្រះស្តេច | ៧៨ | ០១ |
| ព្រៃវែង | ២៤ | ០៣ |
| កំពង់លាវ | ១០ | ០១ |
| ស៊ីធរកណ្តាល | ៨ | ០ |

*ប្រភពពត៌មាន : សាខាកាកបាទក្រហមកម្ពុជា ខេត្តព្រៃវែង*

តាមឯកសាររបស់សាខាកាកបាទក្រហមកម្ពុជាខេត្តព្រៃវែងបានបញ្ជាក់ថានៅទូទាំងខេត្តព្រៃវែងមានទីទួលសុវត្ថិភាពសរុបចំនួន ១៨២ កន្លែង ក្នុងនោះរៀបរយហើយ ដោយមានបង្គន់អនាម័យ និងអណ្តូង ទឹកស្អាត ចំនួន២៤ កន្លែងដែលមាននៅក្នុងស្រុកពាមជរ៍ ០២ ស្រុកពាមរក៍ ០៦ ស្រុកព្រះស្តេច ០១ ស្រុកកំពង់ត្របែក ០១ ស្រុកព្រៃវែង ០៣ ស្រុកកំពង់លាវ ០១ និងស្រុកបាភ្នំ ១០ និងពុំទាន់បានរៀបរយ ចំនួន ១៥៨កន្លែង។ ជាមួយនេះនៅមានទីទួលសុវត្ថិភាពតាមគ្រួសារ ដែលរៀបចំដោយកាកបាទក្រហមកម្ពុជាខេត្តព្រៃវែង មានចំនួន ១២៣ និងរបស់អង្គការ CARE មួយចំនួនទៀត។

## ឃ. មធ្យោបាយដឹកជញ្ជូន

**-មធ្យោបាយដឹកជញ្ជូនធុនតូច** (យោងស្ថិតិភូមិខែធ្នូឆ្នាំ២០០៧)

| ប្រភេទមធ្យោបាយ | ឆ្នាំ២០០៧ | ចំនួនសរុបថ្នាក់ខេត្ត | ផលធៀបគ្រួសារ | ផលធៀបឆ្នាំមុន |
|---|---|---|---|---|
| កង់/កង់រឺម៉ក | 159,956 គ្រឿង | 166,502 គ្រឿង | 1.4 | 1.4 |
| រទេះគោ/រទេះសេះ | 49,314 គ្រឿង | 51,922 គ្រឿង | 5 | 5 |
| ម៉ូតូ/ម៉ូតូរឺម៉ក | 53,261 គ្រឿង | 60,328 គ្រឿង | 4 | 4 |
| ម៉ូតូកង់បី( ត្រីចក្រយានយន្ត) | 272 គ្រឿង | 454 គ្រឿង | 515 | 10,019 |

**-មធ្យោបាយដឹកជញ្ជូនធុនធំ** (យោងស្ថិតិភូមិ)

| ប្រភេទមធ្យោបាយ | ២០០៧ | ចំនួនសរុបថ្នាក់ខេត្ត | ផលធៀបគ្រួសារ | ផលធៀបឆ្នាំមុន |
|---|---|---|---|---|
| **សរុបចំនួនរថយន្ត** | 2697 គ្រឿង | 2,989 គ្រឿង | 78 | 85 |
| រថយន្តកែច្នៃក្នុងស្រុក | 960 គ្រឿង | 987 គ្រឿង | 237 | 240 |
| រថយន្តដឹកជញ្ជូនទំនិញ | 824 គ្រឿង | 937 គ្រឿង | 250 | 280 |
| រថយន្តឈ្នួលដឹកអ្នកដំណើរ | 414 គ្រឿង | 472 គ្រឿង | 495 | 557 |
| រថយន្តសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ | 499 គ្រឿង | 593 គ្រឿង | 394 | 462 |

**-មធ្យោបាយដឹកជញ្ជូនផ្លូវទឹក** (យោងស្ថិតិភូមិ)

| ប្រភេទមធ្យោបាយ | ចំនួនសរុបថ្នាក់ខេត្ត | ផលធៀបគ្រួសារ | ផលធៀបឆ្នាំមុន |
|---|---|---|---|
| ទូកចែវ/អុំ | 13,572 គ្រឿង | 17 | 16 |
| **សរុបទូកម៉ាស៊ីននិងកាណូត** | 4,670 គ្រឿង | 50 | 48 |
| ទូកម៉ាស៊ីននិងកាណូតសម្រាប់នេសាទ | 2,846 គ្រឿង | 82 | 77 |
| ទូកម៉ាស៊ីននិងកាណូតសម្រាប់ដឹកអ្នកដំណើរ | 321 គ្រឿង | 729 | 610 |
| ទូកម៉ាស៊ីននិងកាណូតសម្រាប់ដឹកទំនិញ | 1,503 គ្រឿង | 156 | 163 |

## ង. ប្រព័ន្ធធារាសាស្ត្រ

ទូទាំងខេត្តមានប្រព័ន្ធស្រោចស្រព ២៩០ កន្លែង ទំនប់ ១៣៨ កន្លែង ប្រឡាយ ១៩៧ ខ្សែ ប្រព័ន្ធធារាសាស្ត្រទាំងនេះ អាចស្រោចស្រពបានផ្ទៃដីស្រែ ១០៤.០៤១ ហិកតា ក្នុងនោះស្រូវវស្សាប្រាំង ៤៣.៥០៤ ហិកតា និងស្រូវវស្សាវស្សា ៦០៥៣៧. ហិកតា។ សំណង់ទាំងនោះមាននៅគ្រប់ស្រុកទាំងអស់ ។ ស្រុកពារាំងមានច្រើនជាងគេគឺ ៤៦ កន្លែង ចំណែកស្រុកដែល មានតិចជាងគេមានស្រុកបាភ្នំ ស្រុកព្រះស្តេច និងស្រុកព្រៃវែង ។ ផ្ទៃដីដាំដុះ ៣៣% បានទទួលការស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រ ចំណែកផ្ទៃដី ៦៧ % ពឹងទៅលើទឹកភ្លៀងស្ទើរទាំងស្រុង ។

**ក្រាហ្វិក: <u>ប្រព័ន្ធធារាសាស្ត្រតាមបណ្តាស្រុកក្នុងខេត្តព្រៃវែង ឆ្នាំ២០០៨</u>**

**ចំនួនទំនប់ អាងទឹក ប្រឡាយ ឆ្នាំ២០០៨**




ខេត្តព្រៃវែងមានស្រុក ២ ស្ថិតនៅតាមបណ្តោយទន្លេមេគង្គប្រវែង ៥៧ គ.ម គឺស្រុកពាមរក៍ និងស្រុកពាមជរ ។ ក្រៅពីទន្លេមេគង្គ មានទន្លេតូចៗ ដែលចែកចេញជា៣ខ្សែដូចខាងក្រោម :

- ខ្សែទី ១ : ចេញពីស្រុកពាមរក៍កាត់តាមស្រុកកំពង់លាវប៉ែកខាងលិច ឆ្លងចូលស្រុកពារាំង ប៉ែកខាងលិចទៅដល់ព្រំប្រទល់ស្រុកស៊ីធរកណ្តាល និងខេត្តកំពង់ចាម មានប្រវែង ១០៣គ.ម ។
- ខ្សែទី ២ : ចេញពីស្រុកពាមរក៍ទៅត្បូង តាមព្រំប្រទល់ស្រុកព្រះស្តេច និង ស្រុកពាមជរទៅទល់នឹងប្រទេសវៀតណាមមានប្រវែង ៦៦គ.ម ។
- ខ្សែទី ៣: ចេញពីស្រុកពាមរក៍កាត់តាមព្រំស្រុកបាភ្នំ ស្រុកព្រះស្តេច ទៅស្រុកកំពង់ត្របែក ចេញទៅដល់ព្រំដែនវៀតណាមមានប្រវែង ៦១គ.ម ។

ជារៀងរាល់ឆ្នាំ ទន្លេមេគង្គ និងទន្លេតូចៗ ទាំង៣ខ្សែខាងលើបានហូរនាំមកនូវដីល្បប់ និងជីជាតិមកចាក់លើដីតំបន់វាលទំនាប និងសាយភាយនូវពពួកមច្ឆាជាតិដ៏សំបូរបែប សម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅរបស់ប្រជាជនយើង។ ខេត្តមានបឹងធំ មធ្យម និងតូចៗ ជាច្រើន ដែលជាថ្នក់សម្រាប់ដឹកល់ទឹកទុកប្រើប្រាស់ ស្រោចស្រព ចិញ្ចឹមសត្វ និងរក្សានូវ ពូជត្រី ។ ក្រៅពីទន្លេធំៗ មានបឹងជាច្រើនទៀត ដូចជា : បឹងស្នេហ៍ បឹងពោធិបូរី ប្រទាលបឹងខ្ចី បឹងលើ បឹងខ្សាច់សរ បឹងហា បឹងចាកែ បឹងក្រចាប់ បឹងគំរាង្គ បឹងរកាជួរ បឹងរំលេច បឹងកំពឹងពួយ បឹងសារ៉ៅ បឹងរកា បឹងផុក បឹងឬស្សីរំលេច បឹងព្រៃចាស់ជាដើម។

បឹងទាំងអស់នេះទទួលនូវទឹកជំនន់និងទឹកភ្លៀងហើយ ក៏ជាកន្លែងរក្សានូវទំហំទឹកសម្រាប់ចិញ្ចឹមផល ដំណាំផ្សេងៗ និងជាជំរកសម្រាប់ត្រីពងកូនពេញក្នុងឆ្នាំនិមួយៗ។

មន្ទីរធនធានទឹក និងឧតុនិយមខេត្ត បានបង្ហាញឱ្យឃើញថា ក្នុងខេត្តមានទំនប់-អាងទាំងតូចទាំងធំសរុបចំនួន ១៣៨ កន្លែង (ខ្នាតធំចំនួន ១ កន្លែង មធ្យម ១ កន្លែង និងខ្នាតតូច ១៣៦ កន្លែង ) ប្រឡាយមាន ១៥៦ ខ្សែ និងស្ថានីយ៍បូមទឹកមាន ១១កន្លែង។ សំណង់ទាំងអស់នេះអាច ផ្គត់ផ្គង់ទឹកស្រោចស្រពលើផ្ទៃដីស្រែសរុប ៩៦.៣០៣ហិកតា ស្មើនឹង ៣០%នៃផ្ទៃដីបង្កបង្កើនផល សរុប ៣១០.០០០ ហិកតា ក្នុងនោះ ផ្ទៃដីស្រែប្រាំង ៤៣.៣៦៤ ហិកតា និងផ្ទៃដីស្រែវស្សាចំនួន ៥២.៩៣៩ ហិកតា ។

ទំនប់មាន នៅគ្រប់ស្រុកទាំងអស់ក្នុងខេត្ត ក្នុងនោះស្រុកពារាំងមានចំនួនច្រើនជាងគេ គឺដល់ទៅ ៤៦កន្លែង។ ការប្រើប្រាស់ថវិកាមូលនិធិឃុំ
បច្ចុប្បន្នក៏បានតំរង់ឆ្ពោះភាគច្រើនទៅលើការស្តារប្រព័ន្ធប្រឡាយដើម្បីធានាទឹកសម្រាប់ការបង្កបង្កើន ផលស្រូវផងដែរ ដែលយើងអាចកត់សំគាល់ថា ប្រព័ន្ធធារាសាស្ត្រមានការកើនឡើងនូវលទ្ធភាពស្រោចស្រពជាបន្តបន្ទាប់ ពី ១ឆ្នាំទៅ១ឆ្នាំ ទៅតាមគោលនយោបាយរបស់ រដ្ឋាភិបាលអណត្តិទី៤ ដែលកំណត់ថា ជារដ្ឋាភិបាលធារាសាស្ត្រ។

លទ្ធភាពស្រោចស្រពជារួមមាន ៣០% ដែលបានទទួលការផ្គត់ផ្គង់ទឹកដោយប្រព័ន្ធធារាសាស្ត្រ ចំណែក ៧០%ទៀត គឺពឹងផ្អែកលើទឹកភ្លៀងស្ទើរតែទាំងស្រុង។ តាមទិន្នន័យមូលដ្ឋានដែលប្រមូលបានក្នុងខែធ្នូ ឆ្នាំ២០០៧ ចំនួនប្រជាពលរដ្ឋដែលមានដីស្រែទទួល បានការស្រោចស្រព ពីប្រព័ន្ធធារាសាស្ត្រមាន៤៦.០០៩គ្រួសារ ស្មើនឹង២១.៥១% នៃចំនួនគ្រួសារសរុបក្នុងខេត្ត (ឆ្នាំទៅ ៤៥.៣១៩ គ្រួសារស្មើនឹង១៩,៦០% )។

**ច. ប្រពន្ធ័ទំនាក់ទំនង**

| ល.រ | គោត្តនាម_នាម | ឋានៈ | អង្គភាព | លេខទូរសព្ទ័ |
|---|---|---|---|---|
| ១ | ឯ.ឧ អ៊ុង សាមី | អភិបាលខេត្ត | សាលាខេត្ត | ០១២ ៨៨៧ ៥៥៥ |
| ២ | ល.ផាន់ ចាន់ថុល | អភិបាលរងខេត្ត | សាលាខេត្ត | ០១២ ៣១៧ ១៥៨ |
| ៣ | ល. កែវ សេន | អភិបាលរងខេត្ត | សាលាខេត្ត | ០១១ ៧៤១ ៧០៣ |
| ៤ | ល.សុទ្ធ សឹន | អភិបាលរងខេត្ត | សាលាខេត្ត | ០១២ ៩៧៨ ៧៩៩ |
| ៥ | ល.ស. ទេព សំអូន | អភិបាលរងខេត្ត | សាលាខេត្ត | ០៩២ ៨០៨ ២៦០ |
| ៦ | ល.ថង គឿន | អភិបាលរងខេត្ត | សាលាខេត្ត | ០១២ ៦៨៧ ៤២៦ |
| ៧ | ល. អ៊ី ប៊ុន ឡេង | នាយខុទ្ទកាល័យ | សាលាខេត្ត | ០១២ ៣១៧ ១៥៨ |
| ៨ | ល.ទឹម ផន | ស្នងការ | នគរបាលខេត្ត | ០១២ ៩៨៦ ៦៦៥ |
| ៩ | ល. ហ៊ូ ហ៊ាន | មេបញ្ជាការ | តំបន់សឹករងខេត្ត | ០១២ ៩៥៤ ៩៨៧ |
| ១០ | ល. សុខ គ្រីន | មេបញ្ជាការ | កងរាជអាវុធហត្ថខេត្ត | ០១២ ៨១០ ៩៧៧ |

| | | | | |
|---|---|---|---|---|
| ១១ | លៈ ស សែត | ប្រធានមន្ទីរ | ធម្មការ-សាសនា | ០១២ ៩៨៤ ៣៩២ |
| ១២ | លៈអ៊ុក អ៊ា | ប្រធានមន្ទីរ | ទំនាក់ទំនងសភា | ០១១ ៩២៦ ៦៥០ |
| ១៣ | លៈនៃ សុផល | ប្រធានមន្ទីរ | រៀបចំដែនដី-សំណង់ | ០១២ ៨៩២ ១៤៥ |
| ១៤ | លៈស.ឯម ផល្លា | ប្រធានមន្ទីរ | កិច្ចការនារី | ០១២ ៩៦៤ ៨៨៣ |
| ១៥ | លៈសិរិត មករា | ប្រធានមន្ទីរ | ផែនការ | ០១២ ៩៧២ ២៣៥ |
| ១៦ | លៈ ហ៊ឹម សុផល | ប្រធានមន្ទីរ | អប់រំ យុវជន និង កីឡា | ០១២ ៩៥៥ ៩៣៦ |
| ១៧ | លៈអេង ប៉ាក់ | ប្រធានមន្ទីរ | ទេសចរណ៍ | ០១២ ៩៥៥ ៩៥៩ |
| ១៨ | លៈឈួន ឡេង | ប្រធានមន្ទីរ | សេដ្ឋកិច្ច-ហិរញ្ញវត្ថុ | ០១១ ៩៤១ ០២៨ |
| ១៩ | លៈពេជ្រ ហ៊ាន់ | ប្រធានមន្ទីរ | សុខាភិបាល | ០១២ ៦០១ ៤៨៧ |
| ២០ | លៈ យស់ មុន្នី | ប្រធានមន្ទីរ | កសិកម្ម | ០១២ ៩៥០ ១៥៤ |
| ២១ | លៈ ជុំ សុភី | ប្រធានមន្ទីរ | ធនធានទឹក | ០១២៩០៩ ៦៣៩ |
| ២២ | លៈ កេត ឈាន | ប្រធានមន្ទីរ | ព័ត៌មាន | ០១១ ៧៥៣ ១៩៩ |
| ២៣ | លៈសុខ ផេង | ប្រធានមន្ទីរ | ឧស្សាហកម្ម | ០១២ ៩៥៥ ៣៣៦ |
| ២៤ | លៈទេព សាម៉ន | ប្រធានមន្ទីរ | រតនាគារ | ០១២ ៣៥០ ៣០៤ |
| ២៥ | លៈ លី មុនីនាថ | ប្រធានមន្ទីរ | ប្រៃសណីយ៍ | ០១២ ៩៥៦ ០៥៣ |
| ២៦ | លៈ អឹម ឈឿន | ប្រធានមន្ទីរ | បរិស្ថាន | ០១២ ៩៨៨ ៩១៩ |
| ២៧ | លៈពុត សារ៉ាត | ប្រធានមន្ទីរ | វប្បធម៌ | ០១២ ៨៥៨ ៩១១ |
| ២៨ | លៈតូច សេដ្ឋា | ប្រធានមន្ទីរ | អភិវឌ្ឍជនបទ | ០១២ ៩៥៦ ០៦៧ |
| ២៩ | លៈ នួន ចំរ៉ុង | ប្រធានមន្ទីរ | សាធារណៈការ | ០១២ ៩៥៥ ៣៧៩ |
| ៣០ | លៈសោម សារ៉ន | ប្រធានមន្ទីរ | សង្គមកិច្ច | ០១២ ៣៣០ ៣១៣ |
| ៣១ | លៈ យស់ ចាន់ថុល | ប្រធានមន្ទីរ | ធនាគារ | ០១៦ ៩១៩ ១១៥ |
| ៣២ | លៈជឹម យុន្នី | ប្រធានមន្ទីរ | សាខាពន្ធដារ | ០១១ ៧៣៨ ២២៨ |
| ៣៣ | លៈ សួន សុគន្ធ | ប្រធាន | អគ្គីសនី | ០១២ ៨៣៩ ៨៥៥ |
| ៣៤ | លៈម៉ៅ សុង | ប្រធាន | សាខាកាកបាទក្រហម | ០១២ ២៥០ ៦៥១ |
| ៣៥ | លៈហ៊ុល ចំរើន | លេខាធិការរង | គ.ខ.គ.ម | ០១៦ ៩៥៤ ០១៣<br>០៩២ ៦៤០ ២០៧ |

# ៣. ក្របខ័ណ្ឌការងារយោហ្គោសម្រាប់សកម្មភាព ឆ្នាំ២០០៥-២០១៥ និង ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

## ៣.១ ក្របខ័ណ្ឌការងារយោហ្គោសម្រាប់សកម្មភាពឆ្នាំ២០០៥-២០១៥

តាមសេចក្តីសន្និដ្ឋានលើការត្រួតពិនិត្យមើលពីយុទ្ធសាស្ត្រយោហ្គោហាម៉ា និងលើមូលដ្ឋាននៃសេចក្តីសំរេចនៅឯសន្និសីទពិភពលោក ស្តីពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និងជាពិសេសលើលទ្ធផលរំពឹងទុកដែលបានឯកភាពគ្នា និងគោលដៅយុទ្ធសាស្ត្រ សន្និសីទពិភពលោកបានអនុម័តនូវវិស័យអាទិភាពសម្រាប់សកម្មភាពចំនួន ០៥ ដូចតទៅ:

- ធានាថា ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយជាអាទិភាពថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានដោយមានស្ថាប័នរឹងមាំសម្រាប់អនុវត្ត
- កំណត់ វាយតំលៃ និង ត្រួតពិនិត្យមើលគ្រោះភ័យនៃគ្រោះមហន្តរាយ និង ពង្រឹងប្រពន្ធ័ផ្តល់ពិតមានជាមុន
- ប្រើប្រាស់ចំណេះដឹង នីតិវិធីថ្មីៗ និងការអប់រំ សម្រាប់កសាងនូវវប្បធម៌សុវត្ថិភាព និងភាពធន់ទ្រាំនៅគ្រប់ថ្នាក់
- កាត់បន្ថយកត្តាដែលជាបុព្វហេតុគ្រោះភ័យ
- ពង្រឹងការងារត្រៀមបង្ការ សម្រាប់ធ្វើឱ្យការឆ្លើយតបមានប្រសិទ្ធិភាពនៅគ្រប់ថ្នាក់

# សេចក្តីសង្ខេបស្តីពីក្របខ័ណ្ឌការងារសកម្មភាពហ្យូហ្គោឆ្នាំ ២០០៥-២០១៥: ការកសាងសមត្ថភាពទប់ទល់បានរបស់ប្រជាជាតិ និងសហគមន៍ទៅនឹងគ្រោះមហន្តរាយ

## លទ្ធផលរំពឹងទុក គោលដៅយុទ្ធសាស្ត្រ និងអាទិភាពសំរាប់សកម្មភាព ២០០៥-២០១៥

**លទ្ធផលរំពឹងទុក**

ការកាត់បន្ថយឱ្យបានច្រើននៃការបាត់បង់ដោយគ្រោះមហន្តរាយក្នុងការរស់នៅ និង ទ្រព្យសម្បត្តិ សង្គម សេដ្ឋកិច្ច និងបរិដ្ឋាន នៃសហគមន៍ និងប្រទេស

## គោលដៅយុទ្ធសាស្ត្រ

- សមាហរណកម្មការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងគោលនយោបាយនិងការរៀបចំផែនការអភិវឌ្ឍន៍ប្រកបដោយចិរភាព
- កសាងនិងពង្រឹងយន្តការ ស្ថាប័ន និងសមត្ថភាពដើម្បីកសាង សមត្ថភាពទប់ទល់បានទៅនឹងមុខសញ្ញាគ្រោះថ្នាក់
- រួមបញ្ចូលជាប្រព័ន្ធនៃអភិក្រមការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងការអនុវត្តន៏កម្មវិធី ការត្រៀមបង្ការ ការឆ្លើយតប និងការធ្វើឱ្យមានប្រក្រតីភាពឡើងវិញ

## អាទិភាពសំរាប់សកម្មភាព

### ១. ធានាថា DRRគឺជាអាទិភាព របស់ ជាតិ និងមូលដ្ឋានដែលមានមូលដ្ឋានស្ថាប័ន រឹងមាំសំរាប់ការអនុវត្តន៏

- យន្តការស្ថាប័នកាត់បន្ថយគ្រោះភ័យ នៃគ្រោះមហន្តរាយ (កម្មវិធីជាតិ) ចាត់តាំងអ្នកទទួលខុសត្រូវ
- ការកាត់បន្ថយគ្រោះភ័យនៃគ្រោះ មហន្តរាយ ជាផ្នែកមួយនៃការកសាង គោលនយោបាយ និង ការរៀបចំផែនការរបស់វិស័យ និងពហុវិស័យ
- ច្បាប់ដើម្បីគាំទ្រដល់ DRR
- វិមជ្ឈការនៃការទទួលខុសត្រូវ និង ធនធាន
- ប៉ាន់ប្រមាណអំពីធនធាន និងសមត្ថ ភាពមនុស្ស
- ជំរុញឱ្យរីកចំរើន ការប្តេជ្ញាផ្នែក នយោបាយ
- ការចូលរួមរបស់សហគមន៏

### ២. កំណត់ការ ប៉ាន់ប្រមាណនិងការតាម ដានត្រួតពិនិត្យមុខសញ្ញាគ្រោះមហន្តរាយនិងលើកកំពស់ការផ្តល់ដំណឹងជាមុន

- ការប៉ាន់ប្រមាណគ្រោះភ័យ និង ការធ្វើផែនទីគ្រោះភ័យចំរុះយ៉ាង ល្អិតល្អន់ និង ការចែកចាយ
- ការប្រាប់ឱ្យដឹងពី DRR និងភាពងាយ រងគ្រោះ
- ទិន្នន័យព័ត៌មាននៃស្ថិតិការបាត់បង់
- ការផ្តល់ដំណឹងជាមុន: ទីប្រជុំជនប្រជា ជន ប្រព័ន្ធព័តិមាន គោលនយោបាយ សាធារណៈ
- អភិវឌ្ឍន៏ផ្នែកបច្ចេកវិជ្ជា និងវិទ្យា សាស្ត្រ ការចែករំលែកទិន្នន័យ សង្កេតតាម មូលដ្ឋានលំហរដែនដី ការព្យាករណ៏ និង ការប៉ាន់អាកាសធាតុ ការផ្តល់ដំណឹងជាបន្ទាន់
- តំបន់ និងការផុសចេញគ្រោះភ័យ

### ៣. ប្រើចំណេះដឹង នវកម្មនិងការអប់រំ ដើម្បីកសាងវប្បធម៌សុវត្ថិភាពនិង សមត្ថភាពទប់ទល់បាននៅគ្រប់កំរិត

- ការចែករំលែកព័តិមាន និងកិច្ច សហប្រតិបត្តិការ
- បណ្តាញការងារដែលឆ្លងកាត់ វិន័យ និង តំបន់ ការសន្ទនារ
- ប្រើស្តង់ដាបច្ចេកស័ព្ទ DRR
- ការបញ្ចូល DRR ទៅក្នុង កម្មវិធីសាលារៀន ការអប់រំក្នុង និងក្រៅប្រព័ន្ធ
- ការបណ្តុះបណ្តាល ការរៀនអំពី DRR នៅកំរិតសហគមន៏ អាជ្ញាធរ មូល ដ្ឋាន វិស័យជាគោលដៅការអាចយកប្រើប្រាស់បានស្មើគ្នា
- សមត្ថភាពធ្វើការស្រាវជ្រាវ ពហុគ្រោះភ័យ សេដ្ឋកិច្ចសង្គម ការ អនុវត្តន៏
- ការយល់ដឹងជាសាធារណ និង ប្រព័ន្ធឃោសនា

### ៤. កាត់បន្ថយកត្តាគ្រោះភ័យជាដើម កំណើត

- និរន្តរភាពប្រព័ន្ធអេកូ និងការគ្រប់ គ្រងបរិស្ថាន
- សមាហរណកម្មយុទ្ធសាស្ត្រ DRR ជាមួយការបន្សុំាការប្រែប្រួលអាកាសធាតុ
- សន្តិសុខស្បៀងសំរាប់សមត្ថភាពទប់ ទល់បាន
- សមាហរណកម្ម DRR ទៅក្នុងវិស័យ សុខភាពនិងសុវត្ថិភាពមន្ទីរពេទ្យ
- ការពារសំភារៈឧបទ្ទេសសាធារណៈ ដែលសម្រេចការស្លាប់រស់
- គ្រោងការណ៏ធ្វើឱ្យមានប្រក្រតីភាព ឡើងវិញ និងបណ្តាញសុវត្ថិភាពសង្គម
- ការកាត់បន្ថយភាពងាយរងគ្រោះ ជាមួយនឹងអំណាចជ្រើសរើសចំណូលបែប ផ្សេងៗគ្នា
- យន្តការចែករំលែកគ្រោះភ័យនៃ ហិរញ្ញវត្ថុ-ដៃគូឯកជន សាធារណៈ
- ការរៀបចំផែនការប្រើប្រាស់ដីធ្លី និង ច្បាប់សំណង់
- ផែនការអភិវឌ្ឍន៏ជនបទ និង DRR

### ៥. ពង្រឹងការត្រៀមរៀបចំ គ្រោះ មហន្តរាយ សំរាប់ការឆ្លើយតបប្រកប ដោយប្រសិទ្ធភាព នៅគ្រប់កំរិត

- សមត្ថភាពគ្រប់គ្រងគ្រោះ មហន្តរាយ សមត្ថភាពខាងគោលនយោបាយ បច្ចេកទេស និង ស្ថាប័ន
- ការសន្ទនារសម្របសម្រួល ការផ្លាស់ប្តូរព័តិមានរវាងអ្នកគ្រប់គ្រង គ្រោះមហន្តរាយ និងវិស័អភិវឌ្ឍន៏
- អភិក្រមតំបន់ដើម្បីឆ្លើយតប គ្រោះមហន្តរាយជាមួយចំណុចប្រសព្វគ្នាការកាត់បន្ថយគ្រោះភ័យ
- ពិនិត្យឡើងវិញនូវផែនការត្រៀម រៀបចំ និងផែនការបំរុងទុកជាមុន
- ថវិកាគ្រោះអាសន្ន
- កាស្ម័គ្រចិត្ត និងការចូលរួម

## បណ្តាញទំនាក់ទំនងទៅវិញទៅមក

| | | | |
|---|---|---|---|
| អភិក្រមពហុគ្រោះភ័យ | គោលគំនិតយែនឌ័រ និងភាពផ្សេងៗគ្នានៃវប្បធម៌ | ការចូលរួមពីសហគមន៏ និងអ្នកស្ម័គ្រចិត្ត | ការកសាងសមត្ថភាព និងការផ្ទេរបច្ចេកវិទ្យា |

DRR = Disaster Risk Reduction

www.unisdr.org/wcdr

## ៣.២ ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

### ៣.២.១ ក្របខណ្ឌការងារនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

ផែនការសកម្មភាពដែលបានលើកឡើងដោយផ្អែកលើក្របខ័ណ្ឌការងារសកម្មភាពយោហ្គោ(HFA) គឺបានរៀបចំក្នុងគម្រោង ការគ្រប់ជ្រុងជ្រោយមួយដើម្បីចង្អុលណែនាំអំពីការឆ្លើយតបរបស់អ្នកពាក់ព័ន្ធលើការដោះស្រាយផលប៉ះពាល់នៃគ្រោះមហន្តរាយ ។ ប៉ុន្តែការសង្កត់ធ្ងន់ត្រូវបានតម្រង់ ទៅរកការពង្រឹង សមត្ថ ភាពថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់មូលដ្ឋានសហគមន៍ ដោយកំណត់ទិសដៅឱ្យបានច្បាស់លាស់សម្រាប់ការផ្តួចផ្តើម ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និងដើម្បីគាំទ្រដល់ការសម្រេចឱ្យបាននូវ គោលបំណងកាត់បន្ថយភាពក្រីក្ររបស់ប្រទេស ដែលមាននៅក្នុងផែនការ និងគោលនយោបាយជាតិ(NSDP) ២០០៦-២០១០, NPRS, CMDG, NAPA ២០០៦) ។

សមាសភាគនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយមានចំនួន ០៦សំខាន់ ដែលបានកំណត់ជាអាទិភាព សម្រាប់ប្រទេសកម្ពុជា ដូចខាងក្រោម :

**១-ធានាឱ្យបាននូវការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ គឺជាអាទិភាពនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន**

១.១-រៀបចំដាក់លាក់គោលនយោបាយជាតិ និង នីតិកម្ម ក្នុងការគាំទ្រដល់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

១.២-បង្កើត និងពង្រឹងយន្តការសម្របសម្រួលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ នៅថ្នាក់ជាតិ ឬ"កម្មវិធីជាតិស្តីពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ"

១.៣-សមាហរណកម្មការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងផែនការ និងគោលនយោបាយអភិវឌ្ឍជាតិ

១.៤-ចាត់ចំណាយធនធានសមស្របសម្រាប់ការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ នៅថ្នាក់ជាតិ ។

**២- ពង្រឹងការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយនៅថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋានសហគមន៍**

២.១-វិមជ្ឈការការទទួលខុសត្រូវ និងធនធានសម្រាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

២.២-លើកកម្ពស់ការអនុវត្ត កម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍ ។

**៣- កំណត់ ប៉ាន់ប្រមាណ និងតាមដានត្រួតពិនិត្យមុខសញ្ញាគ្រោះថ្នាក់ និងលើកកម្ពស់ការផ្តល់ដំណឹងជាមុន**

៣.១-ធ្វើការប៉ាន់ប្រមាណ ពីគ្រោះភ័យនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន

៣.២-បង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងគ្រោះមហន្តរាយ

៣.៣-កសាងប្រព័ន្ធផ្តល់ដំណឹងជាមុនពីពហុមុខសញ្ញាគ្រោះថ្នាក់

៣.៤-សហការជាមួយ អង្គការអន្តរជាតិ និង អង្គការថ្នាក់តំបន់ លើកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយគ្រោះ ភ័យនៃគ្រោះមហន្តរាយ ។

**៤- ប្រើប្រាស់ចំណេះដឹង ការរកឃើញថ្មី និងការអប់រំ ដើម្បីកសាងវប្បធម៌សុវត្ថិភាព និងសមត្ថភាពទប់ទល់បាននៅគ្រប់ថ្នាក់**

៤.១-បង្កើតយន្តការសម្រាប់បណ្តាញការងារ និងការផ្លាស់ប្តូរព័ត៌មាន

៤.២-លើកកម្ពស់ការអប់រំ និងបណ្តុះបណ្តាលអំពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

៤.៣-លើកកម្ពស់ការបណ្តុះបណ្តាល យេនឌ័រ និងវប្បធម៌ភាពរហ័សរហួន ដែលជាសមាសភាគរួមរបស់ការកាត់បន្ថយ គ្រោះភ័យនៃគ្រោះមហន្តរាយ

៤.៤-ដំណើរការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ និងបច្ចេកទេសអំពីការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ

៤.៥-បង្កើនការយល់ដឹងជាសាធារណៈ ។

**៥- ការបញ្ជ្រាបការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងគោលនយោបាយ និងកម្មវិធីនានារបស់ក្រសួងពាក់ព័ន្ធ**

៥.១-រួមបញ្ចូលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ទៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ និង និរន្តរភាពបរិស្ថាន

៥.២-សមាហរណកម្មការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ទៅក្នុងកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ

៥.៣-បង្កើនសន្តិសុខស្បៀងដើម្បីបង្កើនសមត្ថភាពធន់ទ្រាំរបស់សហគមន៍

៥.៤-សមាហរណកម្មការធ្វើផែនការការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងវិស័យសុខាភិបាល

៥.៥-លើកកម្ពស់ការកាត់បន្ថយគ្រោះថ្នាក់តាមបែបរចនាសម្ព័ន្ធ និងមិនមែនរចនាសម្ព័ន្ធឱ្យបានសមស្រប

៥.៦-រួមបញ្ចូលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងការធ្វើផែនការប្រើប្រាស់ដីធ្លី និងវិធានការបច្ចេកទេសផ្សេងៗទៀត

៥.៧-បង្កើតទម្រង់បែបបទហិរញ្ញវត្ថុសម្រាប់ការដោះស្រាយគ្រោះភ័យនៃគ្រោះមហន្តរាយ

**៦-ពង្រឹងការត្រៀមរៀបចំសម្រាប់ឆ្លើយតបគ្រោះមហន្តរាយឱ្យមានប្រសិទ្ធភាពនៅគ្រប់ថ្នាក់**

៦.១-ពង្រឹងសមត្ថភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ការត្រៀមរៀបចំ និងឆ្លើយតប

៦.២-បង្កើតនូវយន្តការប្រតិបត្តិការសម្របសម្រួលថ្នាក់តំបន់ សម្រាប់ការងារសង្គ្រោះបន្ទាន់ ដែលហួសពីសមត្ថភាពដោះស្រាយនៅថ្នាក់ជាតិ

៦.៣-រៀបចំ និងធ្វើបច្ចុប្បន្នភាពតាមពេលវេលាលើការរៀបចំផែនការបម្រុងទុក និងការត្រៀមរៀបចំសម្រាប់គ្រោះមហន្តរាយ

៦.៤-បង្កើតឱ្យមានមូលនិធិសង្គ្រោះបន្ទាន់។

## ៣.២.២ តារាងសង្ខេបគម្រោងអាទិភាពកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

| សមាសភាគនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ | | រយៈពេល | | | ថវិកាដាក់លាក់សម្រាប់រយៈពេលខ្លី (000ដុល្លារ) |
|---|---|---|---|---|---|
| | | S | M | L | |
| 1 | **ធានាឱ្យបាននូវ DRR គឺជាអាទិភាពនៅថ្នាក់ជាតិ និង ថ្នាក់មូលដ្ឋាន ប្រកបដោយគ្រឹះនៃស្ថាប័នរឹងមាំសម្រាប់ការអនុវត្តន៍** | | | | |
| 1.1 | រៀបចំដាក់លាក់គោលនយោបាយជាតិ និងនីតិកម្មគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ ថ្នាក់ជាតិ | * | | | 100 |
| 1.2 | ការបង្កើត និងពង្រឹងយន្តការសម្របសម្រួល DRR ថ្នាក់ជាតិ – កម្មវិធីជាតិស្តីពី DRR | * | | | 300 |
| 1.3 | សមាហរណកម្ម DRR ទៅក្នុងគោលនយោបាយ និងការរៀបចំផែនការអភិវឌ្ឍជាតិ | * | | | 100 |
| 1.4 | ការចាត់ចំណាយធនធានសមស្របសម្រាប់ការងារ DRR នៅថ្នាក់ជាតិ | | | | |
| 2 | **ពង្រឹងការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋានសហគមន៍** | | | | |
| 2.1 | វិមជ្ឈការនៃការទទួលខុសត្រូវ និងធនធានសម្រាប់ DRR | | | | |
| 2.2 | លើកកម្ពស់ការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅមូលដ្ឋាន-សហគមន៍ | | | | 550 |
| 3 | **កំណត់ ប៉ាន់ប្រមាណ និងតាមដានត្រួតពិនិត្យមុខសញ្ញាគ្រោះថ្នាក់ និង លើកកម្ពស់ការផ្តល់ដំណឹងជាមុន** | | | | |
| 3.1 | ដំណើរការប៉ាន់ប្រមាណគ្រោះភ័យថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន | | | | |
| 3.2 | បង្កើតប្រព័ន្ធព័តិមានគ្រប់គ្រងគ្រោះមហន្តរាយ | | | | |
| 3.3 | កសាងប្រព័ន្ធផ្តល់ដំណឹងជាមុនពីពហុមុខសញ្ញាគ្រោះថ្នាក់ | | | | |
| 3.4 | សហប្រតិបត្តិការជាមួយ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិនៃកិច្ចខិតខំប្រឹងប្រែងលើ DRR | | | | |
| 4 | **ប្រើប្រាស់ចំណេះដឹង ការរកឃើញថ្មី និងការអប់រំដើម្បីកសាងវប្បធម៌សុវត្ថិភាព និង សមត្ថភាពទប់ទល់បាននៅគ្រប់ថ្នាក់** | | | | |
